# ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង



ដឹកនាំដោយ ឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ស្រាវជ្រាវនិងចងក្រងដោយ ព្រាប ចាន់ម៉ារ៉ា, គង់ វីរៈ, ជី រដ្ឋា

www.elibraryofcambodia.org

ដឹកនាំដោយ៖

ឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

គណៈកម្មការត្រួតពិនិត្យ៖

ឯកឧត្តម អ៊ុន ទឹម

ឯកឧត្តម ចំរើន វ៉ាន់ថា

លោក វិន ឡៃជួ

ស្រាវជ្រាវ និងនិពន្ធដោយ៖

ព្រាប ចាន់ម៉ារ៉ា

គង់ វីរៈ

ជី រដ្ឋា

រចនាទំព័រដោយ៖

ព្រាប ចាន់ម៉ារ៉ា

ផ្សព្វផ្សាយដោយ៖

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំ២០១៣

រក្សាសិទ្ធិ៖

© ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងអ្នកនិពន្ធ

www.elibraryofcambodia.org

00026829

# ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ដឹកនាំដោយ ឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

ស្រាវជ្រាវនិងចងក្រងដោយ ព្រាប ចាន់ម៉ារ៉ា, គង់ វីរៈ, ជី រដ្ឋា

www.elibraryofcambodia.org

www.elibraryofcambodia.org

# មាតិកា


ទំព័រ

គាថាមុខ ........................................ ក

អារម្ភកថា ........................................ ១

ជំពូក១ ៖ ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងសម័យមុន ........................................ ៣

អំពីព្រះមេរុ ........................................ ៤

អំពីព្រះកោដ្ឋ ........................................ ២០

អំពីព្រះមហាបញ្ជា ........................................ ២៣

ពិធីយាងព្រះបរមសពគង់ក្នុងព្រះកោដ្ឋ ........................................ ២៥

អំពីព្រះមរណទាម ........................................ ២៧

អំពីព្រះរាជរថបុស្បក ........................................ ៣០

ក្បួនហែព្រះកោដ្ឋទៅកាន់ព្រះមេរុ ........................................ ៣៥

កិច្ចតម្កល់ព្រះកោដ្ឋក្នុងព្រះមេរុ ........................................ ៤៦

កិច្ចត្រូវធ្វើរាល់ថ្ងៃក្នុងព្រះមេរុ ........................................ ៥០

ព្រះរាជពិធីថ្វាយព្រះភ្លើង ........................................ ៥៤

ពិធីរើសព្រះបរមអដ្ឋិ និងដង្ហែព្រះអង្គារទៅទន្លេ ........................................ ៥៩

កិច្ចយាងព្រះបរមអដ្ឋិគង់ក្នុងព្រះកោដ្ឋពេជ្រ ........................................ ៦១

តម្កល់កោដ្ឋព្រះបរមអដ្ឋិលើមហាបញ្ជាក្នុងព្រះមេរុ ........................................ ៦២

ពិធីហែព្រះបរមអដ្ឋិចូលព្រះបរមរាជវាំង ........................................ ៦៤

អំពីឯកសណ្ឋាន ........................................ ៦៧


www.elibraryofcambodia.org

ជំពូក២ ៖ ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណា
ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ
(ព្រះបរមរតនកោដ្ឋ) .......................................................... ៦៩
ឯកសារពិគ្រោះ........................................................................ ១២៣

www.elibraryofcambodia.org

# អារម្ភកថា

ទំនៀមទម្លាប់ ប្រពៃណីចាប់តាំងពីអ្នកស្រុកស្រែចម្ការធម្មតា អ្នកក្រុងតូចធំ នាម៉ឺន មន្ត្រី រហូតដល់ថ្នាក់ព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គឺសុទ្ធសឹងតែជាមរតកវប្បធម៌រួមរបស់សង្គមជាតិខ្មែរទាំងមូល។ បើពោលអំពីប្រពៃណីរបស់ប្រជាពលរដ្ឋទូទៅក្នុងនគរកម្ពុជា យើងអាចយល់ អាចដឹងខ្លះៗបាន ឬក៏មានអ្នកសិក្សាស្រាវជ្រាវនានាចងក្រង និងផ្សព្វផ្សាយជាហូរហែមក ហើយកាន់តែមានច្រើនឡើងៗ។ រីឯទំនៀមរបស់ព្រះមហាក្សត្រវិញ អ្នកផងទូទៅមិនសូវដឹង មិនសូវឃើញ ព្រមទាំងពុំសូវមានអ្នកសិក្សាស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយឱ្យបានទូលំទូលាយប៉ុន្មានទេ។ ហេតុនេះហើយ មរតកប្រពៃណីដ៏ត្រចះត្រចង់ទាំងនោះហាក់នៅឆ្ងាយ ឬក៏ពុំបានជ្រួតជ្រាបដល់មនុស្សម្នាទាំងពួងគ្រប់ឋានៈឡើយ។ ដូច្នោះ បន្តិចម្តងៗនឹងធ្វើឱ្យយើងខ្វះខាតពត៌មាន ឯកសារ ឬភស្តុតាងផ្សេងៗ សម្រាប់បញ្ជាក់ពីផ្នែកខ្លះនៃវប្បធម៌រុងរឿងរបស់ដូនតាខ្មែរតាមជំនាន់នីមួយៗ។ ក្នុងនោះ ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះមហាក្សត្រគ្រប់ជំនាន់កន្លងមក ក៏ពុំសូវមានឯកសារចងក្រងផ្សព្វផ្សាយឱ្យបានទូលំទូលាយដែរ។

ដោយយល់ឃើញថា ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ជាព្រះមហាវីរក្សត្រដ៏ថ្លៃថ្លានៃព្រះរាជាណាចក្រកម្ពុជា ជាព្រឹត្តិការណ៍យ៉ាងសំខាន់ ធំធេងក្រៃលែងក្នុងសង្គមជាតិខ្មែរ និងជាព្រះរាជពិធីតាមទំនៀមបែបបរមបុរាណរបស់ព្រះមហាក្សត្រខ្មែរដែរ ហើយព្រះរាជពិធីនេះមានដោយកម្រ និងជាគ្រាដ៏សំខាន់ក្នុង

www.elibraryofcambodia.org

ប្រវត្តិសាស្ត្រខ្មែរផងនោះ ទើបក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រៀបចំក្រុមការងារ ធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងបោះពុម្ពជាសៀវភៅផ្សព្វផ្សាយនាឱកាសនេះ។

ការសិក្សាស្រាវជ្រាវទាំងអស់នេះទទួលបាននូវការគាំទ្រ និងការណែនាំដ៏ថ្លៃថ្លាពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈដែលជាសេនាធិការនៃរាជរដ្ឋាភិបាល សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត **ចំពោះសម្តេចអគ្គមហាសេនាបតីតេជោ** ប្រមុខនៃរាជរដ្ឋាភិបាល ដែលសម្តេចតែងតែខិតខំយកចិត្តទុកដាក់ឥតនឿយណាយ ចំពោះវិស័យវប្បធម៌ជាតិយ៉ាងវិសេសវិសាលជារៀងរហូតមក។

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

www.elibraryofcambodia.org

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខៈ......៥១៤ វ.ក

រាជធានីភ្នំពេញ, ថ្ងៃទី...១៧...ខែវិច្ឆិកា...ឆ្នាំ ២០១៦

**សូមគោរពជូន**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

**កម្មវត្ថុ ៖** សូមគោរពជូន ឯកសារជំនួយស្មារតី ស្ដីពី **«ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង»**។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាបជូន **សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា៖ ដោយនាពេលខាងមុខនេះរាជរដ្ឋាភិបាល នឹងមានការរៀបចំព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង ព្រះបរមសព **ព្រះករុណា ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានសិក្សាស្រាវជ្រាវ និងចងក្រង អំពីព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព នៃអតីតព្រះមហាក្សត្រ ព្រមទាំងព្រះបរមសព នៃអតីតសម្ដេចព្រះសង្ឃរាជ នាពេលកន្លងមកដូចជា៖ ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ នាឆ្នាំ១៩២៨ និង ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្ដេចព្រះសុរាម្រឹតនាឆ្នាំ១៩៦០...។ដើម្បីជាឯកសារសម្រាប់ជំនួយស្មារតី ក្នុងការរៀបចំព្រះរាជពិធីនេះ។

បន្ទាប់ពីព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង ព្រះបរមសព **ព្រះករុណា ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** បានបញ្ចប់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្ដេចតេជោ** ដើម្បីរៀបចំចងក្រងជាសៀវភៅ ស្ដីពី **«ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង»** សម្រាប់ទុកជាឯកសារប្រវត្តិសាស្ត្រ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្ដេចតេជោ** មេត្តាជ្រាប និងគោរពសូមមតិណែនាំដ៏ខ្ពង់ខ្ពស់បំផុត។

សូម **សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

www.elibraryofcambodia.org

សូមឧទ្ទិសព្រះរាជកុសលថ្វាយព្រះវិញ្ញាណក្ខ័ន្ធ
ព្រះបរមរតនកោដ្ឋជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

www.elibraryofcambodia.org

# អារម្ភកថា

តាមទំនៀមតរៀងមក ព្រះបរមសពព្រះមហាក្សត្រក្តី ព្រះមហាក្សត្រិយានី ឬព្រះរាជវង្សានុវង្សក្តី ព្រមទាំងព្រះសពសម្តេចព្រះសង្ឃរាជជាដើម គេតែងតែធ្វើព្រះរាជពិធីថ្វាយព្រះភ្លើងជាដរាប។ នេះជាអារ្យធម៌បែបឥណ្ឌា ពិសេសតាមទំនៀមព្រាហ្មណ៍ ដែលខ្មែរធ្លាប់ជ្រួតជ្រាប និងយកមកផ្សំជាមួយវប្បធម៌របស់ខ្លួន យ៉ាងហោចណាស់ក៏ប្រហែលជាតាំងពីសតវត្សទី៣-៤ ឬមុននោះទៀត ហើយបន្តរៀងមក។ ប៉ុន្តែនៅទីនេះយើងខ្ញុំមិនសិក្សាលម្អិតទៅលើប្រវត្តិវែងឆ្ងាយពីសម័យបុរាណព្រេងនាយនោះទេ គឺនិយាយសំដៅតែអំពីប្រពៃណីព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពព្រះមហាក្សត្រ ព្រះមហាក្សត្រី ព្រមទាំងព្រះបរមសពសម្តេចព្រះសង្ឃរាជតៗរៀងរហូតមកប៉ុណ្ណោះ។ តែទោះជាយ៉ាងណា ដើម្បីយល់ពីទំនៀមដែលមានសព្វថ្ងៃនេះ យើងក៏តោងត្រឡប់ទៅមើលអ្វីៗដែលមានពីសម័យបុរាណខ្លះៗផង និងទំនៀមអ្នកស្រុកធម្មតាទូទៅខ្លះៗដែរ ដែលនៅប្រតិបត្តិតរៀងមកដល់សព្វថ្ងៃ។

សៀវភៅនេះចែកចេញជាពីរជំពូកធំៗ គឺជំពូក១ និយាយពីរបៀបរបបក្នុងព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងតាំងពីអំឡុងចុងសតវត្សទី១៩ រហូតមកដល់ជិតចុងសតវត្សទី២០។ ឯជំពូក២ និយាយពីព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ដែលប្រារព្ធនៅនាដើមសតវត្សទី២១នេះ។

នៅក្នុងជំពូក១ យើងខ្ញុំព្យាយាមធ្វើសេចក្តីសង្ខេបឱ្យបានខ្លីៗល្មមងាយយល់ស្រួលស្តាប់ ហើយខិតខំស្វះស្វែងរកឯកសារជាសំណេរ, ជាគំនូរ, ជារូបថតចាស់ថ្មីឱ្យបានច្រើនពីស្ថាប័ននានា ពីសមុច្ច័យឯកជន ពីសៀវភៅផ្សព្វផ្សាយផ្សេងៗដោយកម្រនាពេលកន្លងទៅ ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស យកមកសិក្សា និងដាក់រូប

www.elibraryofcambodia.org

បង្ហាញឡើងវិញ ដើម្បីឲ្យអ្នកអានបានឃើញ ហើយងាយយល់ និងពិចារណាបន្ថែមផង។ ម្ល៉ោះហើយរូបភាពនីមួយៗក៏ជាពត៌មានសម្រាប់អ្នកអានដែរ សូម្បីតែចំណងជើងនៅខាងក្រោមរូបទាំងអស់នោះ ក៏ជាខ្លឹមសារពន្យល់បន្ថែមខ្លះៗទៀតផង។

យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តម ហ៊ឹម ឆែម** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលដឹកនាំការងារនេះ, **ឯកឧត្តម អ៊ុន ទឹម**, **ឯកឧត្តម ចំរើន វ៉ាន់ថា** និង **លោក វីន ឡៃហួ** ដែលជួយត្រួតពិនិត្យ ព្រមទាំងជ្រោមជ្រែងឲ្យកិច្ចការទាំងឡាយបានសម្រេចឡើង។ សូមអរគុណលោកគ្រូ អាំង ជូលាន ដែលផ្តល់យោបល់និងរូបថតមួយចំនួនប្រើក្នុងសៀវភៅនេះ។

យើងខ្ញុំក៏សូមអរគុណចំពោះលោកអ្នកទាំងឡាយ ដែលជួយធ្វើឲ្យការស្រាវជ្រាវ និងចងក្រងសៀវភៅនេះកើតបានជាលទ្ធផល រួមមានលោកហុក សុគុល, អ្នកស្រីគង់ បញ្ញា, លោក Bertrand Porte, លោកជា សុជាតិ, លោកស៊ីយ៉ុន សុភារិទ្ធ, លោកយ៉ាំ សុខលី ជាដើម។ ម្យ៉ាងទៀត សូមអរគុណស្ថាប័នមួយចំនួនដែលអនុញ្ញាតឲ្យប្រើរូបភាពផ្សេងៗ ក្នុងនោះមានសារមន្ទីរជាតិ ភ្នំពេញ, សាលាបារាំងចុងបូព៌ា (EFEO), បណ្ណាល័យ Alençon។ល។

សូមថ្វាយព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខន្ធ
ព្រះមហាវីរក្សត្រ ព្រះបរមរតនកោដ្ឋ។

សូមឲ្យកុសលផលបុណ្យទាំងអម្បាលម៉ានជួយទ្រទ្រង់ប្រទេសកម្ពុជា
និងវប្បធម៌ជាតិបានស្ថិតស្ថេរគង់វង្ស រុងរឿងជារៀងរហូត។

www.elibraryofcambodia.org

## ជំពូកទី១

# ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងសម័យមុន

www.elibraryofcambodia.org

ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះមហាក្សត្រដែលយើងខ្ញុំសិក្សា និងលើកយកមកបង្ហាញសង្ខេបនេះ គឺផ្អែកលើឯកសារតាំងពីព្រះបរមសពព្រះមាតុច្ឆានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ឆ្នាំ១៨៨៣, ព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម (ព្រះសុវណ្ណកោដ្ឋ) ឆ្នាំ១៩០៤_០៦, ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ (ព្រះរាជានុកោដ្ឋ) ឆ្នាំ១៩២៧_២៨, ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស (ព្រះបរមខត្តិយកោដ្ឋ) ឆ្នាំ១៩៤១, ព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត (ព្រះមហាកញ្ចនកោដ្ឋ) ឆ្នាំ១៩៦០, សម្តេចព្រះវររាជជននីតាពិន្ទុរា សុតារ៉េត ឆ្នាំ១៩៦៥។ ក្រៅពីនោះ មានព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពសម្តេចព្រះសង្ឃរាជ និល ទៀង ឆ្នាំ១៩១៤, សម្តេចព្រះសង្ឃរាជ ភុល ទេស ឆ្នាំ១៩៦០ និងសម្តេចព្រះសង្ឃរាជ ជួន ណាត ឆ្នាំ១៩៦៩_៧១ជាដើម។

## អំពីព្រះមេរុ

"ព្រះមេរុ" (និយាយច្លងតាមសម្តីសៀមមកវិញថា "មេន") អ្នកស្រុកទូទៅហៅថា "ភ្នំយោង" គឺជាសំណង់ដែលមានការរចនាផ្សេងៗ ហើយមានកំពូលស្រួចទៅលើ ប្រើសម្រាប់បូជាសព។ សំណង់នេះជានិមិត្តរូបភ្នំព្រះសុមេរុ ដែលជាស្ថានទេព ពោលគឺស្ថានសួគ៌ ដូច្នោះហើយទើបហៅថា "មេរុ" (ភ្នំព្រះសុមេរុ) ឬ "ភ្នំយោង" (ភ្នំដែលជាទីខ្ពង់ខ្ពស់ គឺសួគ៌)។ ដើម្បីយល់រឿងនេះ យើងខ្ញុំសូមនិយាយត្រួសៗអំពីភ្នំព្រះសុមេរុ ឬហៅខ្លីថា "មេរុ" នោះបន្តិចដូចខាងក្រោមនេះសិន។

ក្នុងគំនិតព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា ពោលគឺក្នុងអារ្យធម៌ឥណ្ឌាបុរាណ បើសង្ខេបឲ្យខ្លីមកថា "ចក្រវាល" ឬ "លោកធាតុ" ឬមួយហៅខ្លីថា "លោក"

www.elibraryofcambodia.org

យើងនេះ ជាលំហធំធេង មានអាកាស, ព្រះអាទិត្យ, ព្រះចន្ទ្រ, និងផ្កាយជាដើមច្រើនអនេកអនន្ត ហើយនៅចំកណ្ដាលលោកធាតុនោះ មានភ្នំព្រះសុមេរុ (មេរុ) ដូចជាស្នូលធំ ខ្ពស់ទៅលើយ៉ាងក្រៃលែង ឯបាតក៏ចាក់ចុះទៅក្រោមស្មើនឹងកំពូលដែរ។ រីឯនៅជើងភ្នំព្រះសុមេរុវិញ តែងមានពពួកសត្វមានអំណាចតេជះផ្សេងៗតាំងនៅ ដូចជានាគ, គ្រុឌ, កិន្នរ, កីលេន, សិង្ហ, គជសីហ៍, រាជសីហ៍, ព្យគ្ឃរាជ, ដំរី។ល។ ព្រមដោយពពួកមានជីវិតនានា សឹងជាយក្ស, កុម្ភ័ណ្ឌ, គន្ធព្វជាដើមផង។ ចេញពីជើងភ្នំព្រះសុមេរុនោះមក មានជួរភ្នំព័ទ្ធជុំវិញដូចជាកំពែងមួយជាន់ ហើយផុតពីជួរភ្នំនោះមក មានមហាសមុទ្រព័ទ្ធជុំវិញមួយជាន់ពីក្រៅ លុះផុតពីមហាសមុទ្រមក មានជួរភ្នំមួយជាន់ទៀតរាងទាបជាងមុនបន្តិច និងមានមហាសមុទ្រឆ្លាស់គ្នានឹងជួរភ្នំតៗរហូតដល់៧ជាន់ (រូបលេខ១)។




រូបលេខ១៖ ប្លង់សង្ខេបអំពីលោកធាតុ ឬចក្រវាល មើលពីលើ
(គូរព្រាងដោយ ព្រាប ចាន់ម៉ារ៉ា)។

www.elibraryofcambodia.org

ជួរភ្នំទាំង៧ជាន់នោះហៅថា "ជ័យគិរី" ឯមហាសមុទ្រ៧ជាន់ ហៅថា "ជ័យសិន្ធុ" ហើយសឹងមានពពួកទេពផ្សេងៗគង់នៅទាំងអស់។ នៅក្នុងមហាសមុទ្រខាងក្រៅបង្អស់មានទ្វីប៤ ស្ថិតនៅតាមទិសធំៗទាំង៤ គឺទ្វីបនៅទិសខាងកើតគេហៅថា "បុព្វវិទេហទ្វីប", នៅខាងត្បូងហៅថា "ជម្ពូទ្វីប", នៅខាងលិចហៅថា "អមរគោយានីទ្វីប" និងនៅទិសខាងជើងហៅថា "ឧត្តរកុរុទ្វីប"។ ក្នុងចំណោមទ្វីបទាំង៤នោះ មានតែជម្ពូទ្វីបដែលស្ថិតនៅទិសខាងត្បូងមួយទេ ដែលមានមនុស្សលោកយើងរស់នៅ។ ដូច្នេះសូមចាប់អារម្មណ៍ថា ជម្ពូទ្វីបដែលជាទីមនុស្សរស់នៅ គឺស្ថិតនៅខាងត្បូងភ្នំព្រះសុមេរុ (រូបលេខ១២)។ ចេញផុតពីមហាសមុទ្រខាងក្រៅនោះទៅ គឺជាកណ្ដាប់ចក្រវាល ហើយបន្តទៅក្រៅអំពីនោះទៀត ជាលំហធំល្វឹងល្វើយរកទីបំផុតគ្មាន។ នៅលើភ្នំព្រះសុមេរុនោះ ចែកចេញជាស្ថានផ្សេងៗ ហើយតែងមានទេពនិករនានាគង់នៅតាមលំដាប់ថ្នាក់។




រូបលេខ១២៖ ប្លង់សង្ខេបអំពីទីតាំងភ្នំព្រះសុមេរុ
និងទ្វីបទាំង៤ក្នុងលោកធាតុ (គូរព្រាងដោយ ព្រាប ចាន់ម៉ារ៉ា)។

www.elibraryofcambodia.org

បើនៅក្នុងគំនិតព្រះពុទ្ធសាសនាថា នៅផ្នែកកំពូលភ្នំព្រះសុមេរុដែលជាស្ថានសួគ៌តាមលំដាប់ថ្នាក់នោះ គឺមានស្ថានព្រហ្មខ្ពស់ជាងគេ លុះចេញផុតពីនោះទៅលើទៀតជាស្ថានព្រះនិព្វាន សោះសូន្យទទេ (រូបលេខ១៣_៤)។ រចនាសម្ព័ន្ធ និងទីតាំងរបៀបនេះ ខ្មែរយកមកធ្វើជាក្បួនរៀបចំអ្វីៗក្នុងកិច្ចពិធីផ្សេងៗច្រើនយ៉ាងណាស់ ដ្បិតនោះគឺជា "ធម៌" ជាសណ្ដាប់នៃលោកទាំងមូល ដែលមានលក្ខណៈពេញលេញ ប្រកបដោយភាពត្រឹមត្រូវឥតខ្ចោះ។ នេះមិនខុសអ្វីពីប្រាសាទឡើយ។



រូបលេខ១៣៖ ប្លង់សង្ខេបអំពីលោកធាតុ ឬចក្រវាល មើលពីចំហៀង (រូបស្រង់ពីសៀវភៅ សិក្សាខ្មែរ លេខ១៥ ឆ្នាំ១៩៨៣)។



រូបលេខ១៤៖ ជារូបពង្រីកផ្នែកខាងលើនៃរូបលេខ១៣ មានស្ថានសួគ៌ផ្សេងៗតាមលំដាប់លើភ្នំព្រះសុមេរុ (រូបស្រង់ពីសៀវភៅ សិក្សាខ្មែរ លេខ១៥ ឆ្នាំ១៩៨៣)។

www.elibraryofcambodia.org

ការរៀបចំរចនាសម្ព័ន្ធព្រះមេរុសម្រាប់ថ្វាយព្រះភ្លើងព្រះបរមសពនៃព្រះមហាក្សត្រ ឬភ្នំយោងសម្រាប់បូជាសពមនុស្សទូទៅនោះ គឺគេតែងតែធ្វើឡើងតាមលក្ខណៈលោកធាតុ ឬចក្រវាលដូចពោលពីខាងលើមកនេះឯង។ មុននឹងនិយាយពីព្រះមេរុសម្រាប់ព្រះបរមសពនៃព្រះមហាក្សត្រ ដែលតែងឃើញមានជាធម្មតាហូរហែរៀងមកនោះ យើងខ្ញុំសូមបង្ហាញពីរបៀបរៀបចំមេរុ ឬភ្នំយោងសម្រាប់បូជាសពដែលជាទំនៀមរបស់អ្នកស្រុកធម្មតានិងព្រះសង្ឃនានា ទុកជាការពិចារណាថែមទៀត។

មេរុ ឬភ្នំយោងតែងស្ថិតនៅចំកណ្តាលទីវាល ហើយមានរាជវតិ ដែលជារបងទាបៗរចនាតាមបែបផ្សេងៗព័ទ្ធជុំវិញមេរុ ដើម្បីកំណត់ដែនរបស់មេរុ ឬភ្នំយោងនោះ (រូបលេខ១៥_៦) ដែលខ្លះគេទុកច្រកចេញចូលនៅតាមទិសធំៗទាំងបួន ជួនកាលមានធ្វើខ្លោងទ្វារផង ហើយមានដោតឆត្ររួតនៅអមច្រកចូលនោះទៀត ព្រមទាំងទង់ក្រពើដោតនៅតាមកែងរាជវតិផង (រូបលេខ១៧_៨)។ នៅតាមកែង



រូបលេខ១៥៖ ភ្នំយោង (មេរុ) សម្រាប់បូជាព្រះសពលោកគ្រូចៅអធិការវត្តអធ្វា ខេត្តសៀមរាប ឆ្នាំ១៩៩៥ (រូបថត៖ អាំង ជូលាន)។



រូបលេខ១៦៖ ភ្នំយោង (មេរុ) សម្រាប់បូជាសពអ្នកស្រុកនៅឃុំពាក់ស្នែង ខេត្តសៀមរាប។

www.elibraryofcambodia.org



រូបលេខ១៧៖ ភ្នំយោងតែងមានរាជវតិព័ទ្ធជុំវិញ និងទុកច្រកចូលនៅតាមទិសទាំង៤ ហើយមានឆ័ត្រវែងនៅអមមាត់ច្រក និងនៅតាមកែងរាជវតិ ព្រមទាំងមានទង់ក្រពើដោតនៅតាមកែងរាជវតិផង។ ភ្នំយោងនេះសម្រាប់បូជាសពអ្នកស្រុកនៅវត្តលលៃ ខេត្តសៀមរាប ឆ្នាំ១៩៩៦ (រូបថត៖ អាំង ជូលាន)។



រូបលេខ១៨៖ ភ្នំយោងសម្រាប់បូជាព្រះសពលោកគ្រូចៅអធិការវត្តបាគង ខេត្តសៀមរាប ឆ្នាំ១៩៩៧ (រូបថត៖ អាំង ជូលាន)។

ឬមុមនីមួយៗនៃរាជវតិត្រង់ទិសតូចៗទាំងបួន គេធ្វើ “សមសាន” ដែលជាអាស្រមសម្រាប់ឱ្យព្រះសង្ឃ៤អង្គគង់សូត្រព្រះធម្មនៅពេលតម្កល់សព (រូបលេខ៩_១០)។ ចំណែកឯនៅទិសខាងត្បូងមេរុ គេសាងរោងបុណ្យ ដែលជាកន្លែងមនុស្សមកចូលរួម និងសម្រាប់ធ្វើពិធីផ្សេងៗក្នុងឱកាសបុណ្យនោះ។ បើអ្នកស្រុកនៅសៀមរាប ពិសេសតំបន់អង្គរ ជួនកាលគេសាងរោងបុណ្យនៅខាងត្បូងខិតទៅផ្នែកនិរតីនៃមេរុ ឬភ្នំយោងបន្តិច ដើម្បីឱ្យមេរុបូជាសពនៅទិសឦសាននៃរោងបុណ្យវិញ ដែលជាទិសសំខាន់ក្នុងជំនឿខ្មែរ ពិសេសរឿងស្លាប់និងកើត។ តែជាទូទៅគឺរោងធ្វើបុណ្យតាំងនៅខាងត្បូងភ្នំយោង។ ត្រង់នេះសូមរំលឹកថា សពគេតម្កល់ក្នុងមេរុ (ភ្នំព្រះសុមេរុ) ឯមនុស្សជាទូទៅនៅក្នុងរោងបុណ្យដែលតាំងនៅទិសខាងត្បូងមេរុ ដូចជាជម្ពូទ្វីបដែលមានមនុស្សរស់នៅ ស្ថិតនៅខាងត្បូងភ្នំព្រះសុមេរុដូច្នោះឯង។ និយាយយ៉ាង

www.elibraryofcambodia.org



រូបលេខ៩៖ នៅតាមកែងទាំង៤នៃរាជវតិ មាន "សមសាន" ដែលជាតូបសម្រាប់ព្រះសង្ឃសូត្រព្រះធម្ម (រូបថត៖ អាំង ជូលាន)។



រូបលេខ១០៖ ព្រះសង្ឃសូត្រព្រះធម្មពេលយប់នៅតាមសមសាន ក្នុងឱកាសតម្កល់សពក្នុងភ្នំយោង (រូបថត៖ អាំង ជូលាន)។

នេះពុំមានន័យថា អ្នកស្រុកទាំងអស់ចេះចាំរឿងរ៉ាវលោកធាតុ ឬចក្រវាលគ្រប់ៗគ្នានោះទេ នេះមកពីជាទំនៀម ជាប្រពៃណី តែងតែគោរពតាមគំនិតដើម ធ្វើតាមទម្លាប់ដូនតាតៗគ្នារៀងមកឥតដាច់ ទើបត្រឹមត្រូវឥតល្អៀងដូច្នេះ។

សូមជ្រាបថា ទំនៀមខ្លះរបស់អ្នកស្រុកធម្មតា និងទំនៀមព្រះមហាក្សត្រ មិនខុសគ្នាឆ្ងាយប៉ុន្មានទេ គ្រាន់តែធ្វើតូច ឬធំ គគ្រឹកគគ្រេង ល្អនិងប្រណីតខុសៗគ្នាទៅតាមធនធាន តាមបុណ្យយស ឬឋានៈផ្សេងៗគ្នាប៉ុណ្ណោះ រីឯគោលបំណង និងអត្ថន័យជាទូទៅ គឺមានដូចតែគ្នានោះឯង។

ឥឡូវសូមសង្កេតមើលព្រះមេរុសម្រាប់ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពព្រះមហាក្សត្រនានាជាឧទាហរណ៍ខ្លះ។ បើនៅសម័យអង្គរ យើងឃើញមានចម្លាក់នៅនឹងជញ្ជាំងប្រាសាទបាយ័ន្ត ស.វ.ទី១២ មានបង្ហាញពីព្រះមេរុដែលគេតម្កល់ព្រះកោដ្ឋ មានបែបបទមិនខុសអ្វីប៉ុន្មានពីព្រះមេរុនាសម័យក្រោយៗមកនេះ

www.elibraryofcambodia.org

ឡើយ (រូបលេខ១១)។ លុះក្រោយៗមកទៀត យើងឃើញមានរូបរាងព្រះមេរុខ្លះនៅតាមគំនូរក្នុងព្រះវិហារវត្តចាស់ៗមួយចំនួន (រូបលេខ១២_១៣)។



រូបលេខ១១៖ មេរុតម្កល់សពក្នុងចម្លាក់នៅប្រាសាទបាយ័ន្ត ស.វ.ទី១២។



រូបលេខ១២៖ ព្រះមេរុតម្កល់ព្រះសព ក្នុងគំនូររឿងរាមកេរ្តិ៍នៅថែវជុំវិញព្រះវិហារព្រះកែវមរកត រវាងឆ្នាំ១៩០០។



រូបលេខ១៣៖ ព្រះមេរុតម្កល់ព្រះសព ក្នុងគំនូររឿងរាមកេរ្តិ៍នៅថែវជុំវិញព្រះវិហារព្រះកែវមរកត រវាងឆ្នាំ១៩០០។

www.elibraryofcambodia.org

ព្រះមេរុសម្រាប់តម្កល់កោដ្ឋព្រះបរមសព ត្រូវសាងនៅចំកណ្ដាលទីវាលព្រះមេរុ ដែលតាំងនៅខាងជើងព្រះបរមរាជវាំង។ តួព្រះមេរុជាសំណង់ធំ មានខឿនខ្ពស់ ដំបូលជាបុស្បុកស្រួចទៅលើ ជួនគេធ្វើមុខព្រហ្មដាក់នៅផ្នែកកំពូលផង ហើយមានឆត្ររ័ត (៧រួត) នៅពីលើកំពូលទៀត។ ព្រះមេរុមានច្រកបើកច្រហទៅបួនទិស (ត្រឡែងកែង) ហើយមានដំបូលលយចេញទៅពីលើច្រកទាំង៤។ បើដំបូលនោះមានពីរត្រួតឡើងទៅហៅថា "មេរុមុខដាច់" ហើយនៅច្រកខាងកើតច្រើនមានដំបូលមុខដាច់២ឬ៣ថ្នាក់ លយចេញជាមណ្ឌប វែងជាងច្រកទាំងបីទៀត (រូបលេខ១១៤_១៩)។ នៅតាមកែងទាំង៤ទិសនៃជញ្ជាំងតួព្រះមេរុមានក្បាច់សារពើសូត្រ ហើយនៅលើកម្រាលខឿនព្រះមេរុ គេក្រាលកន្ទេលផ្ដៅឬកន្ទេលកក់សម្រាប់ឱ្យមនុស្សអង្គុយធ្វើ



រូបលេខ១១៤៖ ព្រះមេរុក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម (ព្រះសុវណ្ណកោដ្ឋ) ឆ្នាំ១៩០៦ (រូបថត៖ ?)។



រូបលេខ១១៥៖ ព្រះមេរុក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ (ព្រះរាជានុកោដ្ឋ) ឆ្នាំ១៩២៨ (រូបថត៖ Henri Marchal )។



រូបលេខ១១៦៖ ព្រះមេរុក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សុរាម្រឹត (ព្រះមហាកញ្ចនកោដ្ឋ) ឆ្នាំ១៩៦០(រូបថត៖ ?)។

www.elibraryofcambodia.org



រូបលេខ១៧៖ ព្រះមេរុក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពសម្ដេចព្រះសង្ឃរាជ (គណធម្មយុត្តិកនិកាយ) ភុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៨៖ ព្រះមេរុក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះសពសម្ដេចព្រះរត្នរាជធីតាពិន្ទុភា សុតារ៉េត ឆ្នាំ១៩៦៥ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១៩៖ ព្រះមេរុក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពសម្ដេចព្រះសង្ឃរាជ (គណមហានិកាយ) ជួន ណាត ឆ្នាំ១៩៧១ (រូបថត៖ EFEO, Madeleine Giteau )។

កិច្ចផ្សេងៗ (រូបលេខ២០)។ នៅផ្នែកដំបូលមុខដាច់មានជហ្វា ជង់ក្ដារ ហោជាង ប្រកបដោយក្បូរក្បាច់រចនាល្អប្រណីតណាស់ និងកំពូលបុស្បុក ពិសេសព្រះមេរុសម្រាប់ព្រះបរមសពនៃព្រះមហាក្សត្រ គឺខ្លះមានទាំងរំយោលផ្កាផ្សេងៗនៅនឹងរងស្បូវ ហើយមានរូបមុខព្រហ្ម និងច័ត្ររួតនៅផ្នែកខាងលើជាដើមផង (រូបលេខ២១)។ រីឯព្រះមេរុសម្រាប់ព្រះសពព្រះញាតិវង្ស ឬសម្រាប់ព្រះសពសម្ដេចព្រះសង្ឃរាជជាដើម ជួនកាលនៅលើកំពូលស្រួចមានតែច័ត្ររួត៥រួតប៉ុណ្ណោះក៏មាន (រូបលេខ២២)។ នៅចុងចែងដំបូលតាមថ្នាក់នានាមាននាគសន្ទឹក នាគចែង មានកញ្ចាំងចាំងខ្លែង ហើយនៅក្រោមដំបូលមានអែវ៉ា រាងជាទេពទេយ ឬកិន្នរ ឬមួយគ្រុឌជាដើមហាក់លើកស្ទួយព្រះមេរុឲ្យអណ្ដែតហោះឡើង។ នៅជុំវិញព្រះមេរុគេធ្វើថែវ ឬរាជវតិព័ទ្ធជុំវិញ។ ជួនកាលធ្វើថែវព័ទ្ធជុំវិញពីក្រៅមួយជុំ ហើយនៅចន្លោះថែវនិងតួព្រះមេរុ

www.elibraryofcambodia.org



រូបលេខ២០៖ នៅលើកម្រាលខឿនព្រះមេរុ គេក្រាលកន្ទេលផ្តៅឬកន្ទេលកក់សម្រាប់ឱ្យមនុស្សអង្គុយធ្វើកិច្ចផ្សេងៗ (រូបថត៖ សារមន្ទីរជាតិ, Henri Marchal)។



រូបលេខ២១៖ កំពូលបុស្បកព្រះមេរុមានក្បូរក្បាច់រចនាសព្វបែបយ៉ាងមានរូបមុខព្រហ្ម និងឆ័ត្ររូតនៅផ្នែកខាងលើ (រូបថត៖ សារមន្ទីរជាតិ, Henri Marchal)។



រូបលេខ២២៖ កំពូលបុស្បកព្រះមេរុមានរូបរាងស្រួចនិងមានឆ័ត្ររូតនៅផ្នែកខាងលើ (រូបថត៖ EFEO, Madeleine Giteau)។

គេធ្វើរាជវតិមួយជាន់ទៀត។ រាជវតិគឺជារបងទាបៗរចនាតាមបែបក្បាច់ផ្សេងៗសម្រាប់កំណត់ដែនព្រះមេរុ ដោយទុកច្រកចេញចូលនៅតាមទិសធំៗទាំង៤ (រូបលេខ២៣_២៤)។ រាជវតិនៅជាប់នឹងដី ឃ្លាតឆ្ងាយពីខឿនតួព្រះមេរុ ដើម្បីឱ្យមានបរិវេណលំហ (ចន្លោះតួព្រះមេរុនិងរាជវតិ) អាចហែព្រះកោដ្ឋជាឧត្តរាព័ត៌ជុំព្រះមេរុបាន (សូមកុំច្រឡំរាជវតិនឹងបង្កាន់ដៃដែលនៅលើខឿនតួព្រះមេរុ)។ នៅតាមកែងខាងក្នុងរាជវតិត្រង់ទិសតូចៗទាំង៤ គេធ្វើ "សមសាន" គឺជាអាស្រមសម្រាប់ព្រះសង្ឃ៤អង្គគង់សូត្រព្រះធម្ម (រូបលេខ២៥_២៦)។ នៅអមមាត់ច្រកទាំង៤ទិសនៃរាជវតិ ឬព្រះមេរុ គេដាក់ទ្វារបាល (ឆ្មាំទ្វារ) ជារូបទេព ឬយក្សធំៗអមសងខាងគ្រប់ច្រកទាំង៤ (រូបលេខ២៧_២៨)។ នៅអមមាត់ច្រកទាំង៤ទិសនោះដែរ គឺ

www.elibraryofcambodia.org



រូបលេខ១២៣៖ រាជវតិ (ជារបង់រចនាតាមបែបផ្សេងៗ) ព័ទ្ធជុំវិញព្រះមេរុ ហើយមានខ្លោងទ្វារ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១២៤៖ រាជវតិព័ទ្ធជុំវិញព្រះមេរុ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១២៥៖ សមសាន ជាអាស្រមនៅតាមកែងទាំង៤នៃរាជវតិ សម្រាប់ព្រះសង្ឃគង់សូត្រព្រះធម្ម (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១២៦៖ សមសាន នៅតាមកែងទាំង៤នៃរាជវតិ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១២៧៖ ថ្នាំទ្វារ ឬហៅថា ទ្វារបាល នៅអមសងខាងមាត់ច្រកទាំង៤ទិសនៃព្រះមេរុ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១២៨៖ ថ្នាំទ្វារ ឬហៅថា ទ្វារបាល នៅមាត់ច្រកទាំង៤ទិសនៃព្រះមេរុ (រូបថត៖ ?)។

www.elibraryofcambodia.org

ឃ្លាតពីទ្វារបាលបន្តិច និងនៅតាមកែងរាជវតិ គេដាក់ឆត្រ័ត្រ (បើព្រះមហាក្សត្រ គេដាក់៩រួត បើព្រះញាតិវង្ស ឬសម្ដេចព្រះសង្ឃរាជគេដាក់៧រួត) មានដងខ្ពស់ៗទៅលើ (រូបលេខ២៩_៣០)។ នៅចន្លោះដងឆត្រ័ត្រពីមួយទៅមួយ ឬនៅតាមកែងទាំងបួនផ្នែកខាងក្រៅរាជវតិ គេដាក់ទង់ក្រពើ (ពណ៌ស) ដែលមានដងខ្ពស់ទៅលើ ហើយនៅលើដងទង់នោះជួនកាលគេដាក់រូបហង្ស ជួនកាលទៀតគេដាក់រូបនាគពាំទង់ និងនៅលើរូបហង្សឬនាគ គេដាក់ឆ័ត្ររួត៥រួត (រូបលេខ៣១_៣៣)។



រូបលេខ២៩៖ ឆ័ត្ររួតនៅតាមកែងព្រះមេរុ, គំនូរនៅជញ្ជាំងជុំវិញព្រះវិហារព្រះកែវមរកតនៃព្រះរាជវាំង វាំងឆ្នាំ១៩០០។



រូបលេខ៣០៖ ឆ័ត្ររួតនៅអមសងខាងច្រកចូលនៃរាជវតិទាំង៤ទិស ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ៣១៖ ទង់ក្រពើ ចង់ព្យួរនឹងដងមានរូបហង្សនិងឆ័ត្ររួតនៅខាងលើ ឆ្នាំ១៩២៨(រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ៣២៖ ទង់ក្រពើ ចង់ព្យួរនឹងដងមានរូបនាគនិងឆ័ត្ររួតនៅខាងលើ ឆ្នាំ១៩៦០(រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ៣៣៖ ទង់ក្រពើ ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។

www.elibraryofcambodia.org

ចេញផុតពីរាជវតិមក ជាលំហធំទូលាយបន្តិចព័ទ្ធជុំវិញ ហើយបន្តមកទៀត គឺនៅទិសខាងត្បូងព្រះមេរុ គេសាងព្រះពន្លាធំទូលាយ មានរចនាក្បូរក្បាច់ និងការតុបតែងល្អវិចិត្រ សម្រាប់ព្រះមហាក្សត្រ ព្រះរាជវង្សានុវង្សគង់ប្រថាប់ ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីថ្នាក់ខ្ពស់អញ្ជើញចូលរួមតាមកម្មវិធីនានាក្នុងឱកាសព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងនោះ។ នៅជាប់នឹងព្រះពន្លាគេសាងមន្ទីរភ្ជាប់ជាស្លាបសងខាងច្វេងស្តាំ សម្រាប់អង្គទូតនិងមន្ត្រីអង្គការ ឬភ្នាក់ងារបរទេសនានា។ នៅទិសទាំង៣ផ្សេងទៀត គេសាងជារោង ឬហៅថា "ថែវ" ព័ទ្ធជុំវិញទីវាលព្រះមេរុទាំងមូល ដោយទុកច្រកចេញចូលនៅចំកណ្តាលទិសធំ។ ឯច្រកខាងកើតត្រូវទុកធំទូលាយជាងគេ ដ្បិតសម្រាប់ក្បួនហែព្រះកោដ្ឋចូលព្រះមេរុ និងទទួលព្រះមហាក្សត្រ នាម៉ឺនធំតូចផ្សេងៗ ព្រមទាំងមានកងកិត្តិយសឈរគំនាប់ទទួលអ្នកមានបណ្តាសក្តិ និងរង់ចាំធ្វើវន្ទនាការចំពោះព្រះបរមសពយាងមកដល់ផង (រូបលេខ៣៤)។




រូបលេខ៣៤៖ ប្លង់ទូទៅដែលគេរៀបចំក្នុងទីព្រះមេរុតាមទំនៀម (គូរព្រាងដោយ ព្រាប ចាន់ម៉ារ៉ា)។

www.elibraryofcambodia.org
HUN SEN LIBRARY

ពេលផ្ដើមសាងព្រះមេរុ ត្រូវធ្វើពិធី "ប្រុងពលី" គឺរៀបគ្រឿងពលីការថ្វាយទេពសួមទីស្ថានសាងព្រះមេរុ ដែលអ្នកខ្លះហៅថា "សែនក្រុងពាលី"។ ពិធីនេះត្រូវធ្វើនៅពេលល្ងាច មានរាន រៀបបាយស្រី, ស្លាធម៌, ផ្លែឈើ, បង្អែម, ចម្អាប, ផ្កាភ្ញី, ទៀន, ធូប, ពែ និងគ្រឿងបូជាផ្សេងៗ មានអាចារ្យ មានចាស់ទុំ ព្រមទាំងអ្នកជាអធិបតីផង។ គេសូត្រអញ្ជើញអស់ពពួកទេពនិករនានា ប្រោះស្រាស ប្រាយលាជ ថ្វាយក្រយាបូជា និងមានភ្លេងមួយវង់លេងថ្វាយ។ សែនព្រេនរួចរាល់ហើយ អាចារ្យលើកទឹកផ្តិល យកអំបោះចៅ (ពណ៌ស) ចងដៃអ្នកជាអធិបតីក្នុងពិធី ព្រមទាំងមេជាងដែលត្រូវរៀបចំសាងព្រះមេរុនោះ។ លុះដល់ថ្ងៃលើកសសរកន្ទោងព្រះមេរុ គេក៏មានរៀបធ្វើកិច្ចថ្វាយព្រះពិស្ណុការ និងអញ្ជើញអ្នកជាអធិបតីទាញពួរស្លួយសសរឡើងជាកិច្ចស្រីមង្គលផង (រូបលេខ៣៥_៣៧)។



រូបលេខ១៣៥៖ គ្រោងតួព្រះមេរុសម្រាប់ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ឆ្នាំ១៩២៧ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១៣៦៖ លើកសសរកន្ទោងព្រះមេរុសម្រាប់ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ សាងឆ្នាំ១៩២៧ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១៣៧៖ មានមនុស្សម្នាច្រើន និងអ្នកជាអធិបតីក្នុងឱកាសលើកសសរកន្ទោងព្រះមេរុ សម្រាប់ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ សាងឆ្នាំ១៩២៧ (រូបថត៖ សារមន្ទីរជាតិ)។

www.elibraryofcambodia.org

ជាបន្តបន្ទាប់ទៅទើបគេដំណើរការជាហូរហែទាល់តែហើយស្រេចបាច់។ ក្នុងនោះមានតួព្រះមេរុនៅកណ្ដាល និងខ្លះមានថែវព័ទ្ធជុំវិញភ្ជាប់នឹងសមសាននៅតាមកែងទាំង៤ទិស (រូបលេខ៣៨)។ ព្រះមេរុខ្លះគេពុំសាងថែវខិតចូលក្បែរតួព្រះមេរុនោះទេ គឺសាងខិតថ្វាយមកក្រៅ ហើយសាងរាជវតិចន្លោះតួព្រះមេរុនិងថែវវិញ ទើបមានបរិវេណស្រឡះល្អ ធំទូលាយ ព្រមទាំងមិនធ្វើជញ្ជាំងបិទបាំងថែវទៀតផង ដើម្បីឲ្យមានលំហអាចខ្យល់រត់ទៅមក និងអាចឲ្យមនុស្សម្នាចូលរួមក្នុងព្រះរាជពិធីទាំងមូលមើលឃើញទូទៅបាន។



រូបលេខ៣៨៖ គ្រោងព្រះមេរុដែលមានថែវព័ទ្ធជុំវិញ និងសមសាននៅតាមកែងទាំង៤ទិស សម្រាប់ព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ សាងឆ្នាំ១៩២៧ (រូបថត៖ សារមន្ទីរជាតិ)។

គេសាងព្រះមេរុឲ្យត្រូវតាមទំហំ, កម្ពស់, ប្រវែង, សោភ័ណភាព, តួនាទីផ្នែកនីមួយៗដែលត្រូវប្រើជាក់ស្ដែង និងអត្ថន័យជានិមិត្តរូបផង។ ដូច្នោះអ្នកធ្វើព្រះមេរុតែងពិគ្រោះជាមួយអ្នកធ្វើកិច្ចពិធី ហើយដឹងអំពីទំហំនិងកម្ពស់ព្រះកោដ្ឋ, ទំហំនិងកម្ពស់ព្រះមហាបញ្ជា, ទំហំនិងកម្ពស់ព្រះស្វេតច្ឆត្រ (៧រួត) ដែលត្រូវព្យួរភ្ជាប់នឹងពិតានកណ្ដាលព្រះមេរុនោះ ហើយក៏ដឹងពីចំនួនព្រះសង្ឃនិងអ្នកត្រូវឡើងទៅធ្វើកិច្ចពិធីផ្សេងៗក្នុងព្រះមេរុនោះដែរ។ នៅក្នុងព្រះមេរុមានព្រះមហាបញ្ជា (ជាទម្រត្រួតៗគ្នា៩ថ្នាក់) កម្ពស់ប្រវាង៣_៤ម៉ែត្រ បន្ទាប់ទៅទើបតម្កល់ព្រះកោដ្ឋកម្ពស់ប្រវាង២,៥ទៅ៣ម៉ែត្រពីលើ ហើយពីលើព្រះកោដ្ឋជាលម្ហប្រហែល១,៥ទៅ២ម៉ែត្រ ទើបដល់ព្រះស្វេតច្ឆត្រ (សម្រាប់សម្ដេចព្រះសង្ឃរាជមាន៥រួត ឯព្រះមហាក្សត្រមាន៧

www.elibraryofcambodia.org

រូត) កម្ពស់រវាង២ម៉ែត្រទៅលើទៀត។ ដូច្នេះលម្អក្នុងតួព្រះមេរុពីកម្រាលទៅដល់ពិតាន យ៉ាងហោចណាស់ក៏មានកម្ពស់ប្រមាណ១០_១២ម៉ែត្រដែរ។ រីឯតួព្រះមេរុទាំងមូលពីដីទៅដល់កំពូលមានកម្ពស់យ៉ាងណាក៏រវាងពី៤៥ទៅ៥៥ម៉ែត្រឯណោះ។

ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព ធ្វើឡើងនៅក្នុងព្រះមេរុឲ្យបានត្រឹមត្រូវនោះ គឺក្នុងគំនិត ឬក្នុងបំណងថា សូមឲ្យព្រះវិញ្ញាណក្ខ័ន្ធបានយាងទៅដល់ "សុគតិភព" ពោលគឺស្ថានសួគ៌ (មេរុ) នោះឯង។

## អំពីព្រះកោដ្ឋ

តាមទំនៀមតាំងពីសម័យបុរាណតរៀងមក ព្រះបរមសពព្រះមហាក្សត្រ និងព្រះញាតិវង្សថ្នាក់ខ្ពស់ ព្រមទាំងសម្ដេចព្រះសង្ឃរាជ តែងតែតម្កល់ក្នុងព្រះកោដ្ឋពិសេសនៅពេលធ្វើព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង។ ទំនៀមបែបនេះខ្មែរមានយូរយាររាប់សតវត្សណាស់មកហើយ យ៉ាងហោចណាស់ក៏នៅសម័យអង្គរយើងសេសសល់ភស្តុតាងអំពីរូបរាងកោដ្ឋដូចឃើញមានក្នុងចម្លាក់លើជញ្ជាំងប្រាសាទបាយ័ន្ត ស.វ.ទី១២ (រូបលេខ១៣៩) និងមានកោដ្ឋថ្មជាច្រើន ដែលគេយល់ថាសម្រាប់តម្កល់សពដូចជាកោដ្ឋបច្ចុប្បន្ន ហើយមានទាំងរន្ធសម្រាប់បង្ហូរទឹកផង (រូបលេខ១៤០)។



រូបលេខ១៣៩៖ កោដ្ឋតម្កល់លើមេរុ, ប្រាសាទបាយ័ន្ត ស.វ.ទី១២។



រូបលេខ១៤០៖ កោដ្ឋថ្មនៅបន្ទាយសម្រែ ស.វ.ទី១២ និងតួខាងក្រោមនៃកោដ្ឋថ្មដែលគេរក្សាទុកនៅក្នុងអង្គរធំ។

www.elibraryofcambodia.org

នៅសម័យក្រោយអង្គរគេធ្វើចេតិយខ្លះឲ្យមានរូបរាងស្ទើរដូចកោដ្ឋដែរ គឺទំនងជាគេយកគំរូរូបរាងទូទៅនៃកោដ្ឋនោះមកសាងជាចេតិយនេះឯង (រូបលេខ៤១_៤២)។ ម្យ៉ាងទៀត រូបរាងកោដ្ឋនោះមិនប្រែប្រួលអ្វីពីសម័យអង្គរសោះឡើយ រហូតមកដល់សម័យសព្វថ្ងៃ (រូបលេខ៤៣_៤៧) គឺខ្មែរនៅតែរក្សាមរតកបុរាណដ៏ត្រចះត្រចង់នោះដដែល។ សូម្បីតែធាតុដែលបូជារួចហើយរបស់រាស្ត្រប្រជាសាមញ្ញក៏ច្រើនតែដាក់ក្នុងកោដ្ឋដូច្នោះដែរ គ្រាន់តែគេធ្វើពីវត្ថុធាតុផ្សេងៗគ្នា និងមានទំហំតូចបុំណ្ណោះ (រូបលេខ៤៨)។



រូបលេខ៤១៖ ចេតិយថ្មរាង៨ជ្រុង (សម័យក្រោយអង្គរ) មានទម្រង់ទូទៅស្ទើរដូច កោដ្ឋ។



រូបលេខ៤២៖ កោដ្ឋក្នុងគំនូររឿងរាមកេរ្តិ៍នៅថែវជុំវិញព្រះវិហារព្រះកែវមរកតនៃព្រះបរមរាជវាំង រវាងឆ្នាំ១៩០០។



រូបលេខ៤៣៖ កោដ្ឋក្នុងគំនូររឿងរាមកេរ្តិ៍រវាងពាក់កណ្ដាល ស.វ.ទី២០។



រូបលេខ៤៤៖ ព្រះកោដ្ឋមួយនៅចុងស.វ.ទី១៩? (រូបថត៖ ?)។



រូបលេខ៤៥៖ ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ឆ្នាំ១៩២៨ (រូបថត៖ Henri Marchal)។

www.elibraryofcambodia.org



រូបលេខ១៤៦៖ ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ ?)។



រូបលេខ១៤៧៖ ព្រះកោដ្ឋព្រះបរមសពសម្តេចព្រះសង្ឃរាជ ភុល ទេស (គណធម្មយុត្តិកនិកាយ) ឆ្នាំ១៩៦០ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១៤៨៖ កោដ្ឋដាក់ធាតុ នៅវត្តរការកណ្តាល ខេត្តក្រចេះ។

ព្រះកោដ្ឋរាងមូលបញ្ឈរ ផ្នែកខាងក្រោមរួមតូចបន្តិច ផ្នែកមាត់រីកធំ មានគែមវ័ណ្ឌជុំវិញ ហើយតួកោដ្ឋនេះផ្គុំឡើងពីបន្ទះក្តារតូចៗតម្រៀបគ្នាបញ្ឈរ ហើយមានជើងទម្ររាងខ្ពស់បន្តិច (រូបលេខ១៤៩-៥០) បន្ទាប់មកគេស្រោបលោហៈ ដូចជាទង់ដែង ឬប្រាក់ រួចទឹបមាស ឬមួយគេស្រោបមាសតែម្តង និងឆ្លាក់ក្បូរក្បាច់រចនាយ៉ាងល្អពិចិត្រ (រូបលេខ១៥១)។ រីឯគម្របមូលរាងថ្នាក់ៗស្រួចទៅលើ រាងដូចមកុដ គេធ្វើឆ័ត្ររួត (សម្រាប់ព្រះសង្ឃរាជមាន៥រួត ឯព្រះមហាក្សត្រមាន៧រួត) ដាក់ពីលើកំពូលកោដ្ឋនោះទៀត។ ព្រះកោដ្ឋទាំងមូលមានកម្ពស់ពីបាតដល់កំពូលប្រហែល ២,៥ទៅ៣ម៉ែត្រ។ ព្រះកោដ្ឋនេះតែងតម្កល់នៅលើជើងកោសរាងបួនជ្រុង ដែលប្រកបដោយក្បាច់រចនាផ្សេងៗដែរ។

www.elibraryofcambodia.org



រូបលេខ១៤៩៖ ទ្រូទាប់ខាងក្នុងនៃតួកោដ្ឋផ្តុំឡើងពីបន្ទះក្តារបញ្ឈរតូចៗតម្រៀបគ្នាដែលគេកំពុងធ្វើ (រូបថត៖ ជា សុជាតិ)។



រូបលេខ១៥០៖ ទ្រូទាប់ខាងក្នុងនៃតួកោដ្ឋផ្តុំឡើងពីបន្ទះក្តារ ដែលគេកំពុងធ្វើ (រូបថត៖ ជា សុជាតិ)។



រូបលេខ១៥១៖ ស្រទាប់ខាងក្រៅនៃកោដ្ឋស្រោបសន្លឹកក្បាច់ធ្វើពីលោហធាតុ (រូបថត៖ យ៉ាំ សុខលី)។

# អំពីព្រះមហាបញ្ជា

ព្រះមហាបញ្ជាជាទម្រវាងថ្នាក់ៗត្រួតគ្នាពីធំទៅតូចតាមលំដាប់ពីក្រោមឡើងទៅលើ ហើយប្រកបដោយក្បូរក្បាច់រចនាល្អពិចិត្រ ទីបមាសប្រាលផ្កៅ ភ្លឺភ្លែកយល់យង់ នៅក្នុងព្រះមេរុចំកណ្តាល សម្រាប់តម្កល់កោដ្ឋព្រះបរមសពនៅពីលើ។ បើសម្រាប់ព្រះបរមសពព្រះមហាក្សត្រ គេធ្វើព្រះមហាបញ្ជា៩វួត (រូបលេខ១៥២-៥៤)។ បើសម្រាប់ព្រះបរមសពសម្តេចព្រះសង្ឃរាជ គេច្រើនធ្វើព្រះបញ្ជា៥ឬ៧វួត (រូបលេខ១៥៥)។ រីឯសម្រាប់ព្រះសពព្រះញាតិវង្សវិញ គេច្រើនធ្វើព្រះបញ្ជា៥វួត (រូបលេខ១៥៦)។

www.elibraryofcambodia.org



រូបលេខ១៥២៖ ព្រះមហាបញ្ចាវូត តម្កល់ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ នៅក្នុងព្រះមេរុ ឆ្នាំ១៩២៨ (រូបថត៖ ?)។



រូបលេខ១៥៣៖ ព្រះមហាបញ្ចាវូត សម្រាប់ព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១៥៤៖ ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត តម្កល់លើព្រះមហាបញ្ចាវូត នៅក្នុងព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ ?)។



រូបលេខ១៥៥៖ ព្រះកោដ្ឋព្រះបរមសពសម្តេចព្រះសង្ឃរាជ ភុល ទេស (គណធម្មយុត្តិកនិកាយ) តម្កល់លើព្រះបញ្ចាពវូត នៅក្នុងព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១៥៦៖ ព្រះកោដ្ឋព្រះសពសម្តេចព្រះរត្នរាជធីតា ពិន្ទុរាសុតារ័ត (ជាព្រះញាតិវង្ស) តម្កល់លើព្រះបញ្ចាវូត នៅក្នុងព្រះមេរុ ឆ្នាំ១៩៦៥ (រូបថត៖ EFEO, Madeleine Giteau )។

www.elibraryofcambodia.org

ព្រះមហាបញ្ជរនេះសម្រាប់តម្កល់ព្រះកោដ្ឋព្រះបរមសពក្នុងព្រះមេរុដើម្បីធ្វើពិធីផ្សេងៗច្រើនថ្ងៃ។ លុះដល់ថ្ងៃធ្វើព្រះរាជពិធីថ្វាយព្រះភ្លើង គេរំកិលព្រះកោដ្ឋចុះពីព្រះមហាបញ្ជរនោះ រួចរើរៀបទុកនៅទីផ្សេងមួយអន្លើសិន ទាល់តែស្អែកឡើងធ្វើពិធីរើសព្រះបរមអដ្ឋិរួចរាល់ហើយ ទើបគេតម្លើងព្រះមហាបញ្ជរនេះនៅក្នុងព្រះមេរុឡើងវិញ ដើម្បីតម្កល់កោដ្ឋព្រះបរមអដ្ឋិនៅលើ ធ្វើកិច្ចពិធីផ្សេងៗជាបន្តទៀត។

## ពិធីយាងព្រះបរមសពគង់ក្នុងព្រះកោដ្ឋ

តាមទំនៀមរៀងមក ព្រះបរមសពត្រូវធ្វើកិច្ចថ្វាយស្លាត្រយ អុជទៀនកល្បបន្តបន្ទាប់មកទៀតត្រូវធ្វើកិច្ចរំកិលព្រះសពតម្កល់លើព្រះទែនស្រង់ ហើយធ្វើកិច្ចថ្វាយព្រះសុគន្ធវារីជម្រះព្រះអង្គ។ បន្ទាប់មកថ្វាយព្រះពស្ត្រព្រះភូសា គ្រឿងពេញយស ហើយបង់កាក់មាសក្នុងព្រះឱស និងគ្របព្រះភ័ក្ត្រមាស (រូបលេខ១៥៧)។ ជាបន្តត្រូវធ្វើកិច្ចឲ្យព្រះរាជវង្សានុវង្សសូមខមាទោសចំពោះព្រះបរមសព ហើយក៏យាងចេញទៅ ទើបគេលើកគ្រឿងពេញយសនោះចេញ ក្រុមបារគូ (រូបលេខ១៥៨) រៀបចំ



រូបលេខ១៥៧៖ ព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ដែលគេធ្វើកិច្ចថ្វាយគ្រឿងពេញយស មុនទឹងរៀបចំយាងព្រះអង្គគង់ក្នុងព្រះកោដ្ឋ ឆ្នាំ១៩២៧ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១៥៨៖ ព្រាហ្មណ៍បារគូ រង់ចាំរៀបចំព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ យាងគង់ក្នុងព្រះកោដ្ឋ ឆ្នាំ១៩២៧ (រូបថត៖ សារមន្ទីរជាតិ)។

www.elibraryofcambodia.org

ព្រះបរមសពឲ្យមានឥរិយាបថអង្គុយប្រណម្យ (ដូចទារកនៅក្នុងផ្ទៃ) ហើយរុំសំពត់ស្នបពីក្រៅ ទើបលើកតម្កល់ក្នុងព្រះកោដ្ឋ។ បើពុំបានត្រៀមព្រះកោដ្ឋនោះទុកមុនទេ គេយាងព្រះបរមសពតម្កល់ក្នុងឡតមួយរយៈសិន (រង់ចាំធ្វើព្រះកោដ្ឋហើយ)។ ព្រះកោដ្ឋតម្កល់ព្រះបរមសពនោះ ត្រូវមានកន្លែងសម្រាប់បង្ហូរព្រះបុព្វោចូលទៅក្នុងថូធំមួយ។ យូរសព្ទហ៏មក ទើបគេហែព្រះបុព្វោនោះទៅធ្វើពិធីបូជាក្នុងបារាំកំពូល (បារាំយ៉ត) ឬមួយហែទៅបំផ្លែងក្នុងទឹកទន្លេ។ បើពេលនោះគេធ្វើព្រះកោដ្ឋហើយ គេក៏យាងព្រះបរមសពគង់ក្នុងព្រះកោដ្ឋគ្រានោះឯង ដែលជួនកាលគេធ្វើឲ្យព្រះសពនោះនៅសល់តែព្រះអដ្ឋិប៉ុណ្ណោះ។ ព្រះកោដ្ឋនៃព្រះបរមសពនោះត្រូវតម្កល់លើព្រះបញ្ញាខ្ពស់សមតាមព្រះកិត្តិយសរបស់ព្រះបរមសពនោះផង (រូបលេខ១៥៩-៦០)។ ក្នុងរយៈកាលតម្កល់ព្រះបរមសព គេធ្វើពិធីផ្សេងៗរៀងរាល់រាត្រី រាល់ថ្ងៃ មានរាប់បាត្រ


Cliché Henry

រូបលេខ១៥៩៖ ព្រះកោដ្ឋព្រះបរមសពសម្តេចព្រះសង្ឃរាជ និល ទៀង (គណមហានិកាយ) តម្កល់លើព្រះបញ្ញាក្នុងវត្តឧណ្ណាលោមដើម្បីធ្វើបុណ្យកុសលមួយរយៈ មុននឹងហែទៅកាន់ព្រះមេរុថ្វាយព្រះភ្លើង ឆ្នាំ១៩១៤។



រូបលេខ១៦០៖ ព្រះកោដ្ឋព្រះបរមសពសម្តេចព្រះសង្ឃរាជ ជួន ណាត (គណមហានិកាយ) តម្កល់នៅវត្តឧណ្ណាលោមដើម្បីធ្វើបុណ្យកុសលរយៈពេល២ឆ្នាំ (ស្រុកមានសង្គ្រាម) មុននឹងហែទៅកាន់ព្រះមេរុថ្វាយព្រះភ្លើង ឆ្នាំ១៩៧១ (រូបថត៖ ?)។

www.elibraryofcambodia.org

ប្រគេនចង្ហាន់ ប្រគេនទេយ្យទាន ហើយព្រះសង្ឃសូត្រព្រះធម្ម សូត្រព្រះពុទ្ធគុណ សូត្រសត្តប្បករណ៍ ចម្រើនព្រះពុទ្ធមន្តជាវពហូទេវាជាដើម ថ្វាយព្រះរាជកុសល។ រីឯនាម៉ឺនសពមុខមន្ត្រី គហបតីតូចធំ ខ្ញុំរាជការ បណ្ដារាស្ត្រប្រជា និងរាជទូត អគ្គទូត អគ្គការ។ល។ ក៏អញ្ជើញចូលគាល់ថ្វាយបង្គំ ថ្វាយគ្រឿងសក្ការបូជាចំពោះព្រះបរមសពជាហូរហែតាមលំដាប់លំដោយឥតដាច់រៀងរាល់ថ្ងៃ។

# អំពីព្រះមរណនាម

ការថ្វាយ "ព្រះមរណនាម" ចំពោះព្រះមហាក្សត្រ ជាទំនៀមខ្មែរតាំងពីសម័យបុរាណ គឺយ៉ាងហោចណាស់ក៏តាំងពីដើមសម័យអង្គរ ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី២ ដែលព្រះអង្គយាងចូលទិវង្គតនៅឆ្នាំ៨៥០តរៀងរហូតមក។ ព្រះមរណនាមគេមិនដាក់ដូចឈ្មោះគោរម្យងារមនុស្សនៅរស់ទេ ជាពិសេសពាក្យនៅខាងចុង ក្នុងសម័យបុរាណពុំមានអ្វីក្រៅពីពាក្យថា "លោក" ឬ "បទ" ឯនៅសម័យថ្មីគ្មានពាក្យអ្វីក្រៅពី "កោដ្ឋ" ឡើយ។ ព្រះមរណនាមពុំមែនជាគោរម្យងារទេ គឺជាព្រះនាមចុងក្រោយ សំដៅពីដំណើរយាងទៅកាន់ទេវលោករបស់ព្រះវិញ្ញាណក្ខន្ធ។ នៅសម័យបុរាណនោះ ព្រះមរណនាមនៃព្រះមហាក្សត្រ តែងភ្ជាប់នៅនឹងទេពដែលព្រះរាជាអង្គនោះគោរពបូជាកាលពីព្រះអង្គគង់ព្រះជន្មនៅឡើយ។ ឧទាហរណ៍ ព្រះបាទជ័យវរ្ម័នទី២ គោរពព្រះឥសូរ លុះព្រះអង្គសោយទិវង្គត គេថ្វាយព្រះមរណនាមថា "បរមេសូរ" គឺ "បរម + ឥសូរ"។ ព្រះបាទសូរ្យវរ្ម័នទី២ គោរពបូជាព្រះនារាយណ៍ លុះព្រះអង្គសុគតទៅ គេថ្វាយព្រះមរណនាមថា "បរមវិស្ណុលោក"។ល។ ទាំងនោះបានសេចក្ដីថា បើព្រះមហាកក្សត្រអង្គណាគោរពបូជាទេពណាមួយហើយ ពេលព្រះអង្គ

www.elibraryofcambodia.org

សោយទិវង្គត នឹងយាងទៅបដិសន្ធិនៅក្នុងទេពនោះឯង។ សូមជ្រាបថា ព្រះមហាក្សត្រតែងមានព្រះនាមបីដំណាក់កាល គឺទីមួយជាព្រះនាមកំណើត ដែលដាក់តាំងពីទើបនឹងប្រសូត។ ទីពីរ ព្រះនាមដែលគេប្រកាសថ្វាយជាឱឡារិក នៅក្នុងព្រះរាជពិធីរាជាភិសេកព្រះអង្គជាស្តេចផែនដី។ ទីបី ជាព្រះមរណនាម ដែលគេថ្វាយក្រោយពីព្រះអង្គយាងចូលទិវង្គត។ មកដល់ត្រង់នេះយើងខ្ញុំសូមនិយាយត្រួសៗអំពីទំនៀមរាស្ត្រប្រជាធម្មតាបន្តិច ទុកជាការពិចារណាអំពីអារ្យធម៌ខ្មែរទូទៅ។ បើរាស្ត្រសាមញ្ញ ទោះបីជាគេមិននិយមហៅថាបច្ឆាមរណនាមជាផ្លូវការដូចព្រះមហាក្សត្រក៏ដោយ ក៏យើងមានពាក្យសម្រាប់បញ្ជាក់ថាបុគ្គលនោះស្លាប់បាត់ដែរ ដូចដែលយើងតែងឮគេនិយាយចំពោះអ្នកដែលអនិច្ចកម្មហើយ ដោយមានពាក្យ "ខ្មោច" ពីមុខឈ្មោះ ឬតួនាទីបុគ្គលនោះកាលនៅរស់ដែរ។ ឧទាហរណ៍ពាក្យគេនិយាយថា "ខ្មោចតាងួន" ឬ "ដីនេះជាកេរ្តិ៍ខ្មោចជីតាឯង"។ល។ សុទ្ធតែបញ្ជាក់ថាអ្នកនោះស្លាប់ទៅហើយ។ បើចំពោះព្រះសង្ឃវិញ ពិសេសព្រះគ្រូចៅអធិការវត្តផង គេនិយមប្រើពាក្យថា "ព្រះសព" នៅខាងដើមព្រះនាមព្រះសង្ឃអង្គនោះកាលនៅមានព្រះជន្មដែរ។ ដូច្នេះឃើញថាព្រះមហាក្សត្រតែងមានព្រះមរណនាមជាផ្លូវការ រីឯព្រះសង្ឃនិងប្រជារាស្ត្រទូទៅក៏តងមានពាក្យសម្រាប់បញ្ជាក់ពីមរណភាពនោះដែរ ពោលគឺនេះជាវប្បធម៌ទូទៅរបស់សង្គមខ្មែរ។

នៅខាងក្រោមនេះ យើងខ្ញុំសូមបង្ហាញព្រះមរណនាមព្រះមហាក្សត្រមួយចំនួននៅសម័យអង្គរ ដោយសរសេរជាអក្ខរាវិរុទ្ធសម័យបច្ចុប្បន្ន និងព្រះមរណនាមព្រះមហាក្សត្រសម័យថ្មី។

www.elibraryofcambodia.org

ព្រះមរណនាមព្រះមហាក្សត្រសម័យសម័យអង្គរ៖

- ព្រះបាទជ័យវរ្ម័នទី២ មានព្រះមរណនាមថា "ព្រះបរមេស្វរ"
- ព្រះបាទជ័យវរ្ម័នទី៣ "ព្រះវិស្ណុលោក"
- ព្រះបាទឥន្ទ្រវរ្ម័នទី១ "ព្រះឥស្វរលោក"
- ព្រះបាទយសោវរ្ម័នទី១ "ព្រះបរមសិវលោក"
- ព្រះបាទហសិវរ្ម័នទី១ "ព្រះរុទ្រលោក"
- ព្រះបាទឦសានវរ្ម័នទី២ "ព្រះបរមរុទ្រលោក"
- ព្រះបាទជ័យវរ្ម័នទី៤ "ព្រះបរមសិវបទ"
- ព្រះបាទហសិវរ្ម័នទី២ "ព្រះព្រហ្មលោក"
- ព្រះបាទរាជេន្ទ្រវរ្ម័នទី១ "ព្រះសិវលោក"
- ព្រះបាទជ័យវរ្ម័នទី៥ "ព្រះបរមវីរលោក"
- ព្រះបាទសូរ្យវរ្ម័នទី១ "ព្រះបរមនិព្វានបទ"
- ព្រះបាទហសិវរ្ម័នទី៣ "ព្រះសទសិវបទ"
- ព្រះបាទជ័យវរ្ម័នទី៦ "ព្រះបរមកៃវល្យបទ"
- ព្រះបាទធរណីន្ទ្រវរ្ម័នទី១ "ព្រះបរមនិសកលបទ"
- ព្រះបាទសូរ្យវរ្ម័នទី២ "ព្រះបរមវិស្ណុលោក"
- ព្រះបាទជ័យវរ្ម័នទី៧ "ព្រះមហាបរមសៅគតបទ"
- ព្រះបាទជ័យវរ្ម័នទី៨ "ព្រះបរមេស្វរបទ"។

www.elibraryofcambodia.org

ព្រះមរណាទាមព្រះមហាក្សត្រសម័យថ្មី៖

- ព្រះករុណាព្រះបាទសម្តេចព្រះអង្គឌួង "ព្រះបរមកោដ្ឋ"
- ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម "ព្រះសុវណ្ណកោដ្ឋ"
- ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ "ព្រះរាជានុកោដ្ឋ"
- ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស "ព្រះបរមខត្តិយកោដ្ឋ"
- ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត "ព្រះមហាកញ្ចនកោដ្ឋ"។

ពិធីថ្វាយព្រះមរណទាមនេះធ្វើនៅពេលយាងព្រះបរមសពគង់ក្នុងព្រះកោដ្ឋ ហើយរំកិលឡើងទៅតម្កល់លើព្រះបញ្ចាក្នុងព្រះទីនាំងមហាមន្ទីរនៅផ្នែកខាងក្រោយនៃព្រះទីនាំងទេវាវិនិច្ឆ័យក្នុងព្រះបរមរាជវាំង។ តែបើពុំបានថ្វាយនៅពេលនេះទេ គេធ្វើពិធីថ្វាយព្រះមរណទាមនៅលើព្រះមេរុ ពេលដែលដង្ហែព្រះកោដ្ឋទៅតម្កល់លើព្រះមហាបញ្ចានៅក្នុងព្រះមេរុ (មាននិយាយបន្ថែមនៅខាងក្រោយ)។

## អំពីព្រះរាជរថបុស្បក

នៅសម័យមុនគេច្រើនធ្វើព្រះរាជរថបុស្បករំកិលដោយក្រុមទាហានហ្លួងជាច្រើននាក់រៀបជាជួរកាន់ពួរ ទាញរំកិលព្រះរាជរថឲ្យទៅមុខសន្សឹមៗតាមទំនងឬម្យ៉ាងទៀតព្រះរាជរថនោះទាញដោយសេះច្រើនក្បាល រហូតដល់៥ក៏មាន។ នាសម័យក្រោយមក គេយករថយន្តមករៀបចំតាក់តែងឲ្យមានរូបរាងទៅជាព្រះរាជរថបុស្បក ដើម្បីងាយបរទៅមុខដោយពុំចាំបាច់ប្រើកម្លាំងមនុស្ស ឬសត្វឡើយ។

www.elibraryofcambodia.org

ព្រះរាជរថបុស្បុកតម្កល់ព្រះកោដ្ឋហែទៅកាន់ព្រះមេរុ គេតែងធ្វើជារូបនាគរាជ ឬជារូបហង្ស ដែលជាសត្វក្នុងទេពកថា ជាយានរបស់ទេពនិករ ឬជាសត្វដែលនៅសួគ៌ាល័យ។ ព្រះរាជរថបុស្បុកនាគរាជនោះមានពីរបែប គឺម្យ៉ាងគេធ្វើតួព្រះរាជរថផ្គុំពីរូបនាគរាជជាច្រើន មានតាំងពីជន្ទោល, ព្រែក, ទ្រពង់ថ្នាក់ទី១, ទ្រពង់ថ្នាក់ទី២។ល។ សុទ្ធសឹងតែជារូបនាគរាជទាំងអស់ (រូបលេខ១៦១_៦២)។ ឯព្រះរាជរថបុស្បុកនាគរាជម្យ៉ាងទៀត គឺគេច្នៃរចនាតួរថយន្តឲ្យចេញជារូបនាគរាជធំមួយមានក្បាលខ្ពស់ទៅមុខ និងមានកន្ទុយលយទៅក្រោយ ហើយគេធ្វើរូបនាគ២តូចជាងនោះបន្តិច ដាក់ភ្ជាប់នៅអមសងខាងនាគរាជធំដែលនៅកណ្ដាលនោះផង (រូបលេខ៦៣_៦៤)។ ព្រះរាជរថបុស្បុកខ្លះមានរូបរាងជាសត្វហង្ស ពោលគឺគេយករថយន្តមួយមករៀបចំតុបតែងច្នៃឲ្យមានរាងជាហង្សធំមួយ មានបុស្បុកសម្រាប់តម្កល់



រូបលេខ១៦១៖ ព្រះរាជរថបុស្បុកនាគរាជតម្កល់ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ហែទៅកាន់ព្រះមេរុ ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១៦២៖ ព្រះរាជរថបុស្បុកនាគរាជតម្កល់ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ហែទៅកាន់ព្រះមេរុ ឆ្នាំ១៩២៨ (រូបថត៖ Henri Marchal)។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
www.elibraryofcambodia.org



រូបលេខ១៦៣៖ ព្រះរាជរថបុស្បុកនាគរាជ សម្រាប់តម្កល់ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត ហែទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១៦៤៖ ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត តម្កល់លើព្រះរាជរថបុស្បុកនាគរាជ ក្នុងក្បួនដង្ហែទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ ?)។

ព្រះកោដ្ឋនៅចំកណ្តាលខ្នងហង្សនោះ (រូបលេខ១៦៥_៦៦)។ បុស្បុកនោះមានកម្ពស់ខ្ពស់ និងមានទំហំធំអាចរំកិលព្រះកោដ្ឋចេញចូលបានងាយស្រួល ហើយមានកំពូលស្រួចទៅលើ ព្រមទាំងមានក្បូរក្បាច់ល្អពិចិត្រ មានចង់សន្ទិយានៅតាមមុខទាំងបួន



រូបលេខ១៦៥៖ ព្រះរាជរថបុស្បុករូបហង្ស សម្រាប់ព្រះបរមសពសម្តេចព្រះសង្ឃរាជ ភុល ទេស (គណធម្មយុត្តិកនិកាយ) ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៦៦៖ ព្រះកោដ្ឋព្រះបរមសពសម្តេចព្រះសង្ឃរាជ ភុល ទេស (គណធម្មយុត្តិកនិកាយ) តម្កល់លើព្រះរាជរថបុស្បុករូបហង្ស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។

www.elibraryofcambodia.org

ផង (រូបលេខ១៦៧_៦៨)។ មកដល់ត្រង់នេះ យើងក្រឡេកមើលទៅទីជនបទស្រុកស្រែចម្ការបន្តិចវិញម្តង។ យានសម្រាប់តម្កល់សពហែទៅកាន់ទីបញ្ចុះ ឬទៅកាន់ភ្នំយោងដើម្បីធ្វើកិច្ចបូជានោះ អ្នកស្រុកខ្លះហៅថា “ជើងសាឡី”, ខ្លះហៅថា “រទេះបុស្បុក” ឯខ្លះទៀតហៅថា “រទេះសព” ទៅតាមទម្លាប់រៀងៗខ្លួន។ ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺយានតម្កល់សព គេតែងតែមានការតុបតែងរចនាយ៉ាងប្រណីត ជាពិសេសគឺសម្រាប់ព្រះសពលោកគ្រូចៅអធិការវត្តនានាតែម្តង។ រទេះ



រូបលេខ១៦៧៖ បុស្បុកតម្កល់ព្រះកោដ្ឋទៅលើព្រះរាជរថ (រូបថត៖ Madeleine Giteau )។



រូបលេខ១៦៨៖ បុស្បុកតម្កល់ព្រះកោដ្ឋទៅលើព្រះរាជរថរូបហង្ស ក្នុងក្បួនដង្ហែព្រះកោដ្ឋព្រះបរមសព សម្តេចព្រះសង្ឃរាជ កុល ទេស ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ EFEO, Madeleine Giteau )។

បុស្បុកតម្កល់ព្រះសពនោះច្រើនធ្វើជារូបនាគរាជ (រូបលេខ១៦៩) ឬជារូបរាជសីហ៍ (រូបលេខ១៧០_៧២) ជាដើម។ ដូចបានពោលខ្លះៗមកពីខាងលើហើយថា រាស្ត្រសាមញ្ញក្តី, ទាម៉ឺនតូចធំក្តី, ព្រះសង្ឃក្តី ព្រមទាំងព្រះរាជវង្សានុវង្ស និងព្រះមហាក្សត្រផង គឺពិធីបុណ្យសពប្រព្រឹត្តទៅដូចគ្នា គ្រាន់តែធ្វើតូចឬធំ, មានកិច្ចតិចឬច្រើន

www.elibraryofcambodia.org



រូបលេខ១៦៩៖ រទេះបុស្បុកតម្កល់ព្រះសពព្រះសង្ឃ មានរាងជារូបនាគ (រូបថត៖ EFEO, Madeleine Giteau)។



រូបលេខ១៧០៖ រទេះបុស្បុកតម្កល់ព្រះសពព្រះសង្ឃ មានរូបរាជសីហ៍ក្បាច់ពីមុខ (រូបថត៖ EFEO, Madeleine Giteau)។



រូបលេខ១៧១៖ រទេះបុស្បុកតម្កល់ព្រះសពលោកគ្រូចៅអធិការវត្តអធ្វា មានរូបរាជសីហ៍នាំមុខ ឆ្នាំ១៩៩៥ (រូបថត៖ អាំង ជូលាន)។



រូបលេខ១៧២៖ រូបរាជសីហ៍នាំមុខរទេះបុស្បុកតម្កល់ព្រះសពលោកគ្រូចៅអធិការវត្តបាគង ខេត្តសៀមរាប ឆ្នាំ១៩៩៧ (រូបថត៖ អាំង ជូលាន)។

វែងឬខ្លី, តម្កល់ទុកយូរឬឆាប់ ហើយមានភាពឱឡារិកអធិកអធមទៅតាមធនធានសមរម្យល្មមៗ ឬសម្បើមអស្ចារ្យ ពិចិត្ររចនាប្លែកៗតាមបុណ្យសក្តិ និងកិត្តិយសខុសៗគ្នាប៉ុណ្ណោះ ឬមួយគ្រាន់តែមានទំនៀមផ្សេងគ្នាបន្តិចបន្តួច រីឯអត្ថន័យគឺដូចគ្នា។ ដូច្នោះហើយ រទេះបុស្បុកតម្កល់សពដែលលើកយកមកបង្ហាញខ្លះៗនៅចំណុចនេះចង់បញ្ជាក់ថា រូបសត្វផ្សេងៗដែលគេច្នៃប្រឌិត តុបតែងលម្អទាំងអម្បាលម៉ាន

www.elibraryofcambodia.org

សុទ្ធតែជារូបសត្វក្នុងទេពកថា ជាសត្វនៅភ្នំកៃលាស ភ្នំព្រះសុមេរុ ពោលគឺនៅស្ថានសួគ៌ា ឬជាយានជំនិះរបស់ទេពនិករផ្សេងៗ។ ការដែលយកសត្វទាំងអស់នេះមកដឹកមកនាំព្រះសពនោះទៅកាន់ភ្នំយោង ឬព្រះមេរុ គឺក្នុងន័យហាក់ដូចជាហោះ អណ្តែតក្នុងអាកាសទៅកាន់ស្ថានដ៏ប្រសើរ ស្ថានខ្ពង់ខ្ពស់ ស្ថានទេព សួគ៌ាល័យ ដែលជាទេវលោក ដូចពាក្យដែលគេតែងតែឧទ្ទិសសូមឲ្យវិញ្ញាក្ខ័ន្ធអ្នកចែកស្ថានបានទៅដល់ "សុគតិភព" នោះឯង។

# ក្បួនហែព្រះកោដ្ឋទៅកាន់ព្រះមេរុ

ព្រះកោដ្ឋព្រះបរមសពព្រះមហាក្សត្រគេតែងតម្កល់នៅព្រះទីនាំងមហាមន្ទីរដែលជាផ្នែកខាងក្រោយនៃព្រះទីនាំងទេវាវិនិច្ឆ័យក្នុងព្រះបរមរាជវាំង ដើម្បីធ្វើបុណ្យថ្វាយព្រះរាជកុសលរៀងរាល់ថ្ងៃអស់រយៈជាច្រើនខែ ឬដល់ឆ្នាំផង់នោះលុះដល់ថ្ងៃកំណត់ ត្រូវហែយាងទៅកាន់ព្រះមេរុ។ គេត្រូវរំកិលព្រះកោដ្ឋចុះចាកពីព្រះទីនាំងមហាមន្ទីរតាមទ្វារខាងជើង ចូងកាត់ល្វែងខាងជើងព្រះមហាស្វេតច្ឆ័ត្រហើយចេញតាមទ្វារខាងមុខចំកណ្តាលនៃព្រះទីនាំងទេវាវិនិច្ឆ័យ ចុះតាមកើយខាងមុខ (រូបលេខ៧៣)។ បន្ទាប់មកគេរំកិលព្រះកោដ្ឋឡើងតម្កល់លើព្រះទីនាំងរាជរថយាងចេញពីព្រះបរមរាជវាំងតាមទ្វារជ័យ *(រូបលេខ៧៤)* ដោយមានទាំងព្រះមហាក្សត្រនិងព្រះញាតិវង្សយាងជូនព្រះដំណើរផង *(រូបលេខ៧៥)* ហើយបន្តតាមផ្លូវត្រង់ពីមុខទ្វារជ័យនោះ *(រូបលេខ៧៦)* ទៅកាន់ព្រះរាជរថបុស្បកដែលរង់ចាំនៅក្បែរទីនាំងព្រះអង្គដងកើ។ នៅទីនាំងព្រះរាជរថបុស្បកគេរៀបចំរាំចេននៅលើជើងរ៉ៃទុកជាស្រេច ដើម្បីរំកិលព្រះកោដ្ឋឡើងទៅតម្កល់លើព្រះរាជរថបុស្បកនោះ (រូប

www.elibraryofcambodia.org



រូបលេខ១៣៣៖ រំកិលព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ចុះចាកព្រះទីនាំងទេវាវិនិច្ឆ័យ ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១៣៤៖ តម្កល់ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត លើព្រះរាជរថ ហែចេញពីព្រះបរមរាជវាំងតាមទ្វារជ័យ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១៣៥៖ ព្រះមហាក្សត្រិយានីស៊ីសុវត្ថិ កុសមៈនារីរត្នសិរីវឌ្ឍនា និងសម្តេចព្រះនរោត្តម សីហនុ ព្រមទាំងព្រះញាតិវង្ស យាងដូនព្រះដំណើរព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត ពីក្នុងព្រះបរមរាជវាំងទៅដល់ព្រះរាជរថបុស្បុក ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១៣៦៖ ហែព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត តាមផ្លូវចេញពីទ្វារជ័យត្រង់ទៅកាន់ព្រះរាជរថបុស្បុកដែលរង់ចាំនៅក្បែរព្រះអង្គជង់កើ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។

www.elibraryofcambodia.org

លេខ៣៧_៣៨) ឬរំកិលព្រះកោដ្ឋផ្ទេរពីលើព្រះរាជរថឡើងទៅព្រះរាជរថបុស្បក (រូបលេខ៣៩)។ លុះរួចរាល់ហើយ ទើបក្បួនដង្ហែរំកិលទៅមុខតាមទិសខាងជើង លើផ្លូវព្រះស៊ីសុវត្ថិឆ្ពោះទៅវត្តភ្នំ និងបត់តាមផ្លូវព្រះនរោត្តមមកវិមានឯករាជ្យ បន្តមកកាត់តាមមុខព្រះបរមរាជវាំង ចូលទៅមុខព្រះមេរុនៅក្នុងវាលមេរុ។ ពេលដែលក្បួនរំកិលព្រះកោដ្ឋហែចេញទៅបានបន្តិច ព្រះមហាក្សត្រក៏យាងត្រឡប់ចូលព្រះរាជវាំង ដើម្បីត្រៀមយាងចេញទទួលវិញនៅពេលក្បួនហែមកដល់មុខព្រះរាជវាំង។



រូបលេខ៣៧៖ គេរៀបចំរាំងទេរលើជើងរ៉ៃ ភ្ជាប់ទៅព្រះរាជរថបុស្បករួចជាស្រេច រង់ចាំរំកិលព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ឡើងទៅតម្កល់លើព្រះរាជរថបុស្បកនោះ ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ៣៨៖ រំកិលព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ឡើងទៅតម្កល់លើព្រះរាជរថបុស្បក ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។

រូបលេខ៣៩៖ រំកិលព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រិត ផ្ទេរពីព្រះរាជរថ (ហែចេញមកពីព្រះបរមរាជវាំង) ទៅតម្កល់លើព្រះរាជរថបុស្បក ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



www.elibraryofcambodia.org

ក្បួនហែព្រះកោដ្ឋទៅកាន់ព្រះមេរុធ្វើឡើងខុសគ្នាខ្លះៗទៅតាមសម័យកាល តែគោលធំៗមានដូចគ្នា។ ក្បួនហែតាមលំដាប់លំដោយដែលយើងខ្ញុំសូមស្រង់សង្ខេប ចំណុចសំខាន់ៗពីឯកសារផ្សេងៗនាសម័យក្រោយមក មានដូចខាងក្រោមនេះ។

នៅខាងមុខព្រះរាជរថបុស្បុក៖

- នៅខាងមុខបំផុតនៃក្បួនហែ មានអ្នកកាន់ទង់ជាតិ ទង់សាសនា និងទង់ព្រះមហាក្សត្រ។ ជាបន្តបន្ទាប់មកទៀតមានដូចជា៖
- ក្រុមទាហានជើងគោក។
- ក្រុមទាហានជើងទឹក។
- ក្រុមទាហានជើងអាកាស។
- កងរក្សាព្រះអង្គ (ទាហានហ្លួង)។
- កងសេះតែងគ្រឿង (រូបលេខ១៨០)។
- កងដំរីតែងគ្រឿង (រូបលេខ១៨១_៨២)។



រូបលេខ១៨០៖ ទ័ពសេះក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះសុរាម្រឹត ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១៨១៖ ទ័ពដំរីក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះសុរាម្រឹត ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១៨២៖ ដំរីក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះសុរាម្រឹត ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។

www.elibraryofcambodia.org

- ភ្លេងក្លងធ្នះ ឬក្លងខែក (រូបលេខ១៨៣), ភ្លេងពិណពាទ្យ (រូបលេខ១៨៤) , ភ្លេងខ្មែរ (រូបលេខ១៨៥)។
- ជួនកាលមានថែមទាំងភ្លេងឆៃយ៉ាំ, ភ្លេងឈ្នួង គ្រឹង ទំពួន, ភ្លេងចាម្ប, ភ្លេងចិន, ភ្លេងយួន។ល។
- ក្រុមព្រាហ្មណ៍ (បារគូ) កាន់កូនស្គរពីងពាំងគ្រលែងទៅមកៗ (រូបលេខ១៨៦)។



រូបលេខ១៨៣៖ ក្រុមភ្លេងក្លងធ្នះ ឬខ្លះហៅថាភ្លេងក្លងខែក ក្នុងក្បួនហែព្រះបរមសពសម្តេចព្រះសង្ឃរាជ ភុល ទេស (គណធម្មយុត្តិកនិកាយ) ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១៨៤៖ ក្រុមភ្លេងពិណពាទ្យក្នុងក្បួនហែព្រះបរមសពសម្តេចព្រះសង្ឃរាជ ភុល ទេស ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១៨៥៖ ក្រុមភ្លេងខ្មែរក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១៨៦៖ ក្រុមព្រាហ្មណ៍បារគូ គ្រលែងកូនស្គរពីងពាំងក្នុងក្បួនហែព្រះបរមសពព្រះបាទសម្តេចព្រះ សុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash. edu.au/hdl/1959)។

www.elibraryofcambodia.org

- អ្នកវាយស្គរមហោរធឹកចំនួន២។
- រូបសត្វផ្សេងៗក្នុងទេពកថា ដែលជាយានជំនិះទេពនិករនានា ឬជាសត្វនៅនាជើងភ្នំព្រះសុមេរុ (ឬព្រៃហេមពាន្ត) ដែលជាសត្វមកពីសួគ៌ាទាយ មកហែហាមព្រះបរមសពយាងទៅកាន់ព្រះមេរុ។ សត្វទាំងនោះមានដូចជា រាជសីហ៍, គជសីហ៍, នាគរាជ, ព្យគ្ឃរាជ, ឧសភារាជ, គីលេន, ហង្ស, កិន្នរ, ហត្ថីលិង្គ, ព្លាវ័ណ, រមាស, ប្រើស, ពពែ។ល។ (រូបលេខ១៨៧-១៩០) ដែលជួនកាលគេតម្កល់ត្រៃនៅពីលើខ្នងរូបសត្វទាំងអស់នោះផង។



រូបលេខ១៨៧៖ រូបសត្វផ្សេងៗក្នុងទេពកថា ជាសត្វមកពីសួគ៌ា ប្រើក្នុងក្បួនហែព្រះបរមសពព្រះមាតុច្ឆានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទៅកាន់ព្រះមេរុ ឆ្នាំ១៨៨៣ (រូបគំនូរ៖ បណ្ណាល័យ Alençon)។



រូបលេខ១៨៨៖ រូបសត្វផ្សេងៗក្នុងទេពកថា ជាសត្វមកពីសួគ៌ា ប្រើក្នុងក្បួនហែព្រះបរមសពព្រះមាតុច្ឆានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទៅកាន់ព្រះមេរុ ឆ្នាំ១៨៨៣ (រូបគំនូរ៖ បណ្ណាល័យ Alençon)។

www.elibraryofcambodia.org



រូបលេខ៨៩៖ រូបសត្វផ្សេងៗក្នុងទេពកថា ជាសត្វមកពីស្ងួតា ប្រើក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះ ស៊ីសុវត្ថិ ទៅកាន់ព្រះមេរុ ឆ្នាំ១៩២៨ (រូបថត៖ Henri Marchal)។



រូបលេខ៩០៖ រូបរាជសីហ៍តម្កល់នៅមុខព្រះមេរុសម្រាប់ព្រះសព សម្តេចព្រះវត្ថរាជធីតា ពិន្ទុរា សុគារ័ត ឆ្នាំ១៩៦៥ (រូបថត៖ EFEO, Madeleine Giteau )។

- ក្រែស្នែងព្រះសង្ឃអភិធម្ម មានគោកថ្កល់ក្រាំងអភិធម្ម (រូបលេខ ៩១)។
- ក្រុមបុរសស្លៀកក្បិនពណ៌ស ពាក់អាវកុតស ពាក់មួកលំផក កាន់ផ្កាឈូក។
- រូបសត្វរមាសទាំភ្លើង (រូបលេខ៩២_៩៣)។ សត្វរមាសនេះយើងដឹងស្រាប់មកថា ក្នុងទេពកថានិងសិល្បៈខ្មែរបុរាណ គឺជាយានជំនិះរបស់ព្រះអគ្និ គឺព្រះភ្លើងនេះឯង ដូចដែលយើងតែងសង្កេតឃើញជារឿយៗនៅតាមចម្លាក់បុរាណនានាជាច្រើន។
- ក្រែស្នែងខ្ចឹមច័ន្ទទ័។



រូបលេខ៩១៖ ក្រែស្នែងព្រះសង្ឃអភិធម្មក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះ សុរាម្រឹត ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។

www.elibraryofcambodia.org



រូបលេខ៩២៖ រូបសត្វរមាសនាំភ្លើងក្នុងក្បួនហែព្រះបរមសពព្រះមាតុច្ឆានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទៅកាន់ព្រះមេរុ ឆ្នាំ១៨៨៣ (រូបគំនូរ៖ បណ្ណាល័យ Alençon)។



រូបលេខ៩៣៖ រូបសត្វរមាសនាំភ្លើងក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ ?)។

- ត្រែស្នែងអ្នកប្រាយលាជ (រូប១៩៤)។

- ត្រែស្នែងអ្នកទូលស្បូវភ្លាំង (រូបលេខ៩៥) គឺពីមុនមកប្រហែលជាគេទូលស្បូវភ្លាំងដូចទំនៀមអ្នកស្រុកទូទៅដូច្នោះដែរ តែព្រះសពព្រះរាជានៅសម័យក្រោយមក យើងឃើញគេកាន់សំពត់ទូ (ជាយោង) ដាក់លើតោកជាំមួយបន្ទាយទៅភ្ជាប់នឹងព្រះកោដ្ឋទៅវិញ ហើយមានអ្នកកាន់ដងទ្រូបន្តបន្ទាប់គ្នាកុំឲ្យដក់ដល់ដី (រូបលេខ៩៦_៩៧)។



រូបលេខ៩៤៖ ត្រែស្នែងអ្នកប្រាយលាជក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះសុរាម្រឹត ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ៩៥៖ ត្រែស្នែងអ្នកទូលស្បូវភ្លាំងភ្ជាប់ទៅនឹងព្រះកោដ្ឋ ក្នុងក្បួនហែព្រះបរមសពព្រះមាតុច្ឆានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ទៅកាន់ព្រះមេរុ ឆ្នាំ១៨៨៣ (រូបគំនូរ៖ បណ្ណាល័យ Alençon)។

www.elibraryofcambodia.org



រូបលេខ៩៦៖ ក្រែស្នែងអ្នកកាន់គោកដាក់សំពត់ទូ (ផារយាង) បន្ទាយទៅភ្ជាប់នឹងព្រះកោដ្ឋ មានអ្នកកាន់ដងទ្រូបន្តបន្ទាប់គ្នាកុំឱ្យដក់ដល់ដី ក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះសុរាម្រឹត ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ៩៧៖ ក្រែស្នែងអ្នកកាន់គោកដាក់សំពត់ទូ (ផារយាង) ក្នុងក្បួនហែព្រះបរមសពសម្ដេចព្រះសង្ឃរាជ ភុល ទេស (គណធម្មយុត្តិកនិកាយ) ទៅកាន់ព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។

នៅលើព្រះរាជរថបុស្បក៖

- ព្រះញាតិវង្សគង់ទប់ព្រះកោដ្ឋពីមុខមួយអង្គ ពីក្រោយមួយអង្គ (រូបលេខ៩៨)។
- អ្នកបាំងក្លស់សខាងឆ្វេងម្នាក់ ខាងស្ដាំម្នាក់។
- អ្នកកាន់បាំងសែងខាងឆ្វេងម្នាក់ ស្ដាំម្នាក់ (ជួនកាលនៅខាងក្រោយម្នាក់ទៀត)។
- អ្នកកាន់ចាមរ, បៃមន់, សែនត្ប៊ូន, ភូតាន, វីជនី។ល។ នៅខាងឆ្វេងមួយជួរ នៅខាងស្ដាំមួយជួរ។
- អ្នកកាន់អភិរម្យ (ពណ៌សចំមាស) ៤នាក់អង្គុយតាមមុម។
- ទេពនិករ (ក្រុមអ្នករបាំតែងគ្រឿង) អង្គុយប្រណម្យជាជួរអមសងខាងព្រះកោដ្ឋម្ខាង៨នាក់ ទុកដូចជាទេព្ដាមកហែហាមព្រះបរមសពយាងទៅកាន់ទេវស្ថាន (រូបលេខ៩៩)។

www.elibraryofcambodia.org



រូបលេខ១៩៨៖ ព្រះកោដ្ឋតម្កល់លើរាជរថ មានព្រះអង្គម្ចាស់យុគន្ធរ ទប់ព្រះកោដ្ឋពីមុខ និងព្រះអង្គម្ចាស់ឥស្សរាវង្ស ទប់ព្រះកោដ្ឋពីក្រោយ ក្នុងក្បួនហែព្រះបរមសពព្រះមាតុច្ឆានៃព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម ទៅកាន់ព្រះមេរុ ឆ្នាំ១៨៨៣ (រូបគំនូរ៖ បណ្ណាល័យ Alençon)។



រូបលេខ១៩៩៖ អ្នករបាំតែងតួជាទេពនិករមកហែហមព្រះបរមសពយាងទៅព្រះមេរុ ក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះសុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ ?)។

www.elibraryofcambodia.org

នៅលើផ្លូវអមសងខាងព្រះរាជរថបុស្បក៖

- អ្នកកាន់ខ្សែព្រួរនិងទង់នាគ, ទង់ម្កុរ, ទង់ឥន្ទ្រីយ៍, ទង់ក្អែប។ល។ (រូបលេខ១០០)។

- អ្នកកាន់គ្រឿងហែ មានអភិរម្យម្ខាង។៨, ១២, ១៦ ឬលើសពីនេះ, ចាមរ, បៃមន់, សែនត្វ័ន, ភូតាន។ល។ (រូបលេខ១០១) និងស្បង់កាច់ផ្ការដើម។

- អ្នកកាន់ទង់ក្របើពណ៌ស ម្ខាង។៤ឬ៨ (រូបលេខ៦២)។



រូបលេខ១០០៖ អ្នកកាន់ខ្សែព្រួរ និងទង់នាគ, ទង់ម្កុរ, ទង់ឥន្ទ្រីយ៍, ទង់ក្អែប ក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ យាងទៅកាន់ព្រះមេរុ ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។

រូបលេខ១០១៖ អ្នកកាន់ចាមរ, បៃមន់, សែនត្វ័ន, ភូតាន។ល។ នៅអមព្រះរាជរថបុស្បកតម្កល់ព្រះកោដ្ឋ ក្នុងក្បួនហែព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស យាងទៅកាន់ព្រះមេរុ ឆ្នាំ១៩៤១ (រូបថត៖ ?)។



នៅខាងក្រោយព្រះរាជរថបុស្បក៖

- ក្រុមព្រះញាតិវង្ស (នៅជាប់ព្រះរាជរថបុស្បក)។

- ព្រះរាជាគណសង្ឃគណមហានិកាយម្ខាង និងគណធម្មយុត្តិកនិកាយម្ខាង។

- អ្នកបួសក្នុងសាសន៍ផ្សេងៗ មានលោកសង្ឃចិន, ចាម្ប, យួន។ល។

- ក្រុមអ្នករាជការផ្សេងៗ និងបន្តពីក្រោយដោយក្រុមរាស្ត្រប្រជាទូទៅ។ល។

www.elibraryofcambodia.org

តាមផ្លូវដង្ហែក្បួននោះ មានក្រុមព្រះសង្ឃរង់ចាំសូត្រធម៌បង្សុកូលថ្វាយព្រះបរមសព នៅតាមចំណុច២_៣កន្លែង។ រីឯនៅអមសងខាងផ្លូវមានសិស្ស, និស្សិត, គ្រូ, មន្ត្រី តូចធំ ខ្ញុំរាជការ, បណ្ដារាស្ត្រប្រជាទូទៅរង់ចាំប្រណម្យថ្វាយបង្គំព្រះបរមសពជាហូរហែឥតដាច់។

## កិច្ចតម្កល់ព្រះកោដ្ឋក្នុងព្រះមេរុ

ពេលហែព្រះកោដ្ឋទៅដល់ពីមុខព្រះមេរុ ព្រះមហាក្សត្រនិងព្រះញាតិវង្សយាងចេញពីព្រះពន្លាដែលនៅខាងត្បូងព្រះមេរុ ទៅថ្វាយបង្គំទទួលព្រះបរមសព និងសូមយាងចូលទៅកាន់ព្រះមេរុតាមច្រកទិសខាងកើត។ គេត្រូវរំកិលព្រះកោដ្ឋផ្ទេរពីព្រះរាជរថបុស្បុកទៅលើព្រះរាជរថ (រូបលេខ១០២) ហើយហែតាមទិសឧត្តរព័ត៌៣ជុំព្រះមេរុ ដោយមានព្រះញាតិវង្សយាងដង្ហែតាមផង។ លុះហែគ្រប់៣ជុំហើយ ព្រះរាជរថតម្កល់ព្រះកោដ្ឋឈប់នៅពីមុខជណ្ដើរខាងកើតនៃព្រះមេរុ (រូបលេខ១០៣) បន្ទាប់មកគេរំកិលព្រះកោដ្ឋតម្កល់លើរ៉ាចេន រួចរំកិលឡើងទៅតម្កល់លើព្រះមហា



រូបលេខ១០២៖ រំកិលព្រះកោដ្ឋផ្ទេរពីព្រះរាជរថបុស្បុកទៅលើព្រះរាជរថនៅមុខព្រះមេរុ, ព្រះបរមសពព្រះករុណាព្រះសុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១០៣៖ ព្រះរាជរថតម្កល់ព្រះកោដ្ឋហែតាមទិសឧត្តរព័ត៌៣ជុំព្រះមេរុរួចមកឈប់នៅមុខជណ្ដើរខាងកើតនៃព្រះមេរុ, ព្រះបរមសពព្រះករុណាព្រះព្រះសុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ ?)។

www.elibraryofcambodia.org

បញ្ជា៩វត្ត ដែលនៅកណ្ដាលព្រះមេរុនោះ។ នៅពេលរំកិលព្រះកោដ្ឋផ្ទេរចុះឡើងពីកន្លែងមួយទៅកន្លែងមួយ គេច្រើនលើកគម្របព្រះកោដ្ឋចេញ ហើយយកសំពត់ល្បើកមាសមកគ្របព្រះកោដ្ឋបណ្ដោះអាសន្នសិន ដើម្បីឱ្យងាយធ្វើការ ដល់តម្កល់ព្រះកោដ្ឋនៅទីមួយស្រួលបួលហើយ ទើបគេលើកគម្របព្រះកោដ្ឋទៅគ្របវិញ។

ក្នុងការរំកិលព្រះកោដ្ឋឡើងទៅតម្កល់លើព្រះមហាបញ្ជាគេត្រូវប្រើរ៉ៃ (រូបលេខ១០៤) ដែលភ្ជាប់នឹងជើងទម្រ (រាំចេទ) សម្រាប់ថ្កល់ព្រះកោដ្ឋ ហើយមានពួរទាញឡើង និងមានអ្នករុញអមឡើងខ្លះផង (រូបលេខ១០៥_១០៦)។ លុះឡើញទៅដល់លើហើយ គេរំកិលព្រះកោដ្ឋទៅតម្កល់លើព្រះមហាបញ្ជា និងក្រុមបារគូថ្វាយស័ង្ខ (រូបលេខ១០៧_១០៨) រួចទើបគេដោះយករាំចេទនិងជើងរ៉ៃទាំងអស់ទៅរក្សាទុកមួយអន្លើសិន (រូបលេខ១០៩)។ លុះរៀបចំស្រេចបាច់កាលណា ព្រះកោដ្ឋ



រូបលេខ១០៤៖ ជើងរ៉ៃសម្រាប់រំកិលព្រះកោដ្ឋឡើងទៅលើព្រះមហាបញ្ជាសម្រាប់ព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ឆ្នាំ១៩២៨ (រូបថត៖ Henri Marchal)។



រូបលេខ១០៥៖ ទាញពួររំកិលរាំចេទលើជើងរ៉ៃឡើងទៅព្រះមហាបញ្ជាសាកត្រៀមសម្រាប់ព្រះបរមសពព្រះករុណាព្រះស៊ីសុវត្ថិ ឆ្នាំ១៩២៨ (រូបថត៖ ?)។



រូបលេខ១០៦៖ រំកិលព្រះកោដ្ឋព្រះបរមសពសម្ដេចព្រះសង្ឃរាជ ជួន ណាត ឡើងទៅលើព្រះមហាបញ្ជា ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។

www.elibraryofcambodia.org



រូបលេខ១០៧៖ វិកិលព្រះកោដ្ឋផ្ទេរពីជើងរ៉ែទៅលើព្រះមហាបញ្ចាទៅកណ្តាលព្រះមេរុ ហើយក្រុមបារគូថ្វាយស័ង្ខ ព្រះបរមសពសម្តេចព្រះសង្ឃរាជ ភុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau)។



រូបលេខ១០៨៖ តម្កល់ព្រះកោដ្ឋលើព្រះមហាបញ្ចាទៅព្រះមេរុ ព្រះបរមសពព្រះករុណាព្រះសុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១០៩៖ តម្កល់ព្រះកោដ្ឋលើព្រះមហាបញ្ចាហើយដោះយករ៉ាទេទនិងជើងរ៉ែទៅរក្សាទុកមួយអន្លើសិន, ព្រះបរមសពសម្តេចព្រះសង្ឃរាជ ភុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau)។

នោះស្ថិតនៅលើព្រះមហាបញ្ចាខ្ពស់ក្នុងព្រះមេរុ (រូបលេខ១១០_១១២) ដោយមានតំពត់ទូ (ផារយោង) តភ្ជាប់ពីមាត់ព្រះកោដ្ឋចុះមកក្រោមដាក់លើតោកធំមួយ សម្រាប់ឱ្យព្រះសង្ឃកាន់ទ្រពេលសូត្រធម៌ផ្សេងៗ។ ព្រះមហាក្សត្រ, ព្រះរាជវង្សានុវង្ស, នាម៉ឺនសព្វមុខមន្ត្រីធំៗ យាងនិងអញ្ជើញឡើងព្រះមេរុ ហើយបើពុំទាន់បានថ្វាយព្រះមរណនាមកាលពីយាងព្រះបរមសពគង់ក្នុងព្រះកោដ្ឋ នៅឯព្រះទីនាំមហាមន្ទីរក្នុងព្រះទីនាំងទេវាវិនិច្ឆ័យនៅឡើយ គេត្រូវប្រកាសព្រះរាជក្រឹត្យតាំងព្រះមរណនាមថ្វាយព្រះបរមសពដែលគង់ក្នុងព្រះកោដ្ឋតម្កល់លើព្រះមហាបញ្ចាក្នុងព្រះមេរុនាគ្រានេះ។ បន្ទាប់មកព្រះមហាក្សត្រ, ព្រះញាតិវង្ស, នាម៉ឺនធំៗនៅក្នុងព្រះមេរុ រីឯអ្នករាជការ, ទាហាន, និស្សិត, បណ្ឌារាស្ត្រទាំងអម្បាលត្រូវឈរនៅតាមថែវ និង

www.elibraryofcambodia.org



រូបលេខ១១០៖ ព្រះកោដ្ឋតម្កល់លើព្រះមហាបញ្ជា៩វូតក្នុងព្រះមេរុដើម្បីធ្វើកិច្ចពិធីផ្សេងៗ។ ព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ឆ្នាំ១៩២៨ (រូបថត៖ Henri Marchal)។



រូបលេខ១១១៖ ព្រះកោដ្ឋតម្កល់លើព្រះ មហាបញ្ជា៧វូតលើព្រះមេរុ ព្រះបរមសពសម្តេចព្រះសង្ឃរាជ កុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១១២៖ ព្រះកោដ្ឋតម្កល់លើព្រះបញ្ជា៥វូតលើព្រះមេរុ ព្រះបរមសពសម្តេចព្រះវត្ថរាជធីតាពិន្ទុរា សុតាវេត ឆ្នាំ១៩៦៥ (រូបថត៖ EFEO, Madeleine Giteau )។

តាមទីនានាក្នុងព្រះមេរុធ្វើកិច្ចថ្វាយបង្គំព្រះបរមសព៣ដងព្រមៗគ្នាតាមចង្វាក់គង។ ប៉ុន្តែបើគេបានប្រកាសថ្វាយព្រះមរណនាមស្រេចកាលពីគ្រាមុនរួចហើយ គឺនៅពេលនេះគេគ្រាន់តែធ្វើពិធីថ្វាយបង្គំតាមចង្វាក់គងប៉ុណ្ណោះ។ លុះចប់ស្រេចហើយ ព្រះមហាក្សត្រយាងត្រឡប់ចូលព្រះបរមរាជវាំង (រូបលេខ១១៣) ឯព្រះញាតិវង្ស និងនាម៉ឺនសព្វមុខមន្ត្រីក៏ត្រឡប់ទៅវិញជាហូរហែដែរ។ ចំណែកឯនៅទីព្រះមេរុ មានធ្វើកិច្ចពិធីតាមលំដាប់លំដោយ។



រូបលេខ១១៣៖ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសមៈនារីរត្នសិរីវឌ្ឍនា និងសម្តេចព្រះ នរោត្តម ស៊ីហនុ យាងចុះចាកព្រះមេរុ និវត្តទៅកាន់ព្រះបរមរាជវាំងវិញ។ ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះសុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។

www.elibraryofcambodia.org

# កិច្ចត្រូវធ្វើរាល់ថ្ងៃក្នុងព្រះមេរុ

ព្រះកោដ្ឋដែលគេដង្ហែមកតម្កល់លើព្រះមហាបញ្ជាក្នុងព្រះមេរុហើយនោះ ត្រូវទុកធ្វើកិច្ចពិធីផ្សេងៗ និងឲ្យមនុស្សម្នាគ្រប់ជាន់ថ្នាក់ចូលទៅថ្វាយបង្គំគោរពព្រះបរមសពរវាង៧ថ្ងៃ។ យើងខ្ញុំសូមបង្ហាញកិច្ចសំខាន់ៗនៅទីនេះមាន៖

- ម៉ោង១២ថ្ងៃត្រង់៖ ធ្វើកិច្ចថ្វាយក្រយាព្រះស្ងោយ គឺមានអ្នករៀបចំព្រះក្រយាដាក់លើពានតម្កល់លើតុក្បែរជើងព្រះមហាបញ្ជា មានព្រះញាតិវង្ស ឬអ្នកជាតំណាងអុជទៀនធូបថ្វាយ និងសូមយាងព្រះអង្គទទួលព្រះក្រយាស្ងោយ ហើយក្រុមបារគូផ្លុំស័ង្ខថ្វាយ ព្រមទាំងមាននារី២នាក់អង្គុយបក់ផ្លិតវីជនី និងមានស្រីច្រើននាក់អង្គុយយំយាម រៀបរាប់ធ្វើបទ និងមានថ្វាយភ្លេងក្លងឆ្នៈកំដរផង ហើយមានអ្នកនៅគាល់បម្រើដូចកាលគ្រាដែលព្រះអង្គគង់ព្រះជន្មនៅឡើយ (រូបលេខ១១៤_១១៥)។ យើង



រូបលេខ១១៤៖ កិច្ចផ្សេងៗធ្វើនៅក្នុងព្រះមេរុរៀងរាល់ថ្ងៃ ថ្វាយព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ឆ្នាំ១៩២៨ (រូបថត៖ ?)។



រូបលេខ១១៥៖ កិច្ចផ្សេងៗធ្វើនៅក្នុងព្រះមេរុរៀងរាល់ថ្ងៃ ថ្វាយព្រះបរមសពសម្ដេចព្រះវរក្សត្រាជធីតា ពិន្ធុរា សុគារ៉េត ឆ្នាំ១៩៦៥ (រូបថត៖ EFEO, Madeleine Giteau )។

www.elibraryofcambodia.org

ខ្ញុំសូមបង្ហាញទំនុកឃំយាមមួយកំណាត់ខ្លី ដែលជាផ្នែកខាងដើម ចម្លងចេញពីសម្លេង ដែលថតដោយលោក ហ្សាក់ ប្រុយនេ កាលពីទសវត្ស១៩៦០៖

ព្រះអម្ចាស់ខ្ញុំអើយ! ព្រះអម្ចាស់លើត្បូង! ព្រះអម្ចាស់ខ្ញុំអើយ!
ពេលនេះធ្លាប់ស្រង់ ធ្លាប់សោយគម្រាន្ត ខ្ញុំម្ចាស់នេះចាន ធ្លាប់គាល់បម្រើ។
ព្រះអម្ចាស់ខ្ញុំអើយ! ព្រះអម្ចាស់លើត្បូង! ព្រះអម្ចាស់ខ្ញុំអើយ! ...

ទំនៀមថ្វាយក្រយាព្រះស្ងោយចំពោះព្រះបរមសពនេះ ក៏មិនខុសអ្វីពីព្រះសពសម្តេចព្រះសង្ឃរាជ និងព្រះគ្រូចៅអធិការវត្តឡើយ ហើយសូម្បីតែរាស្ត្រសាមញ្ញក៏មានកិច្ចប្រហែលគ្នានេះដែរ គ្រាន់តែពុំមានរបៀបរបបធំដុំដូច្នេះ។ បើព្រះសពលោកគ្រូចៅអធិការវត្តនៅតាមស្រុក តាមតំបន់ខ្លះ ដូចយ៉ាងសៀមរាបជាដើម គេក៏ធ្វើកិច្ចដូចព្រះមហាក្សត្រដែរ គឺមានអ្នកលើកចង្ហាន់ បង្អែម ចម្អាប ម្ហូប ចាប៉ី ប្រគេននៅក្នុងទីតម្កល់ព្រះសព (រូបលេខ១១៦) ដោយមានអ្នកអង្គុយបក់ផ្លិត (រូបលេខ១១៧) មានក្រុមភ្លេងខ្មែរប្រគំ ច្រៀងរៀបរាប់ផ្សេងៗផង (រូបលេខ១១៨)។



រូបលេខ១១៦៖ កិច្ចប្រគេនចង្ហាន់ចំពោះព្រះសព ក្នុងពិធីបុណ្យរំលាយព្រះសពព្រះគ្រូចៅអធិការវត្តអធ្វា នៅខេត្តសៀមរាបឆ្នាំ១៩៩៥ ដូចគ្នានឹងកិច្ចថ្វាយក្រយាព្រះស្ងោយចំពោះព្រះបរមសពនៃព្រះមហាក្សត្រដែរ (រូបថត៖ អាំង ជូលាន)។



រូបលេខ១១៧៖ មានអ្នកអង្គុយបក់ផ្លិតពេលធ្វើកិច្ចប្រគេនចង្ហាន់ក្នុងពិធីបុណ្យរំលាយព្រះសពព្រះគ្រូចៅអធិការវត្តអធ្វា នៅខេត្តសៀមរាបឆ្នាំ១៩៩៥ ដូចគ្នានឹងកិច្ចថ្វាយក្រយាព្រះស្ងោយនៃព្រះមហាក្សត្រដែរ (រូបថត៖ អាំង ជូលាន)។

www.elibraryofcambodia.org



រូបលេខ១១៨៖ មានអ្នកលេងភ្លេងនៅពេលធ្វើកិច្ចប្រគេនចង្ហាន់ចំពោះព្រះសព ក្នុងពិធីបុណ្យរំលាយព្រះសពព្រះគ្រូចៅអធិការវត្តអធ្វា នៅខេត្តសៀមរាប ឆ្នាំ១៩៩៥ ដូចគ្នានឹងកិច្ចថ្វាយព្រះក្រយាស្ងោយចំពោះព្រះបរមសពនៃព្រះមហាក្សត្រ ដែលតែងមានអ្នកលេងភ្លេងថ្វាយដែរ (រូបថត៖ អាំង ជូលាន)។

- ម៉ោង៥ល្ងាច៖ កិច្ចព្រះសង្ឃសូត្រសត្តប្បករណ៍ (រូបលេខ១១៩)។

- ម៉ោង៥:៣០ល្ងាច៖ កិច្ចព្រះសង្ឃទេសនានៅក្នុងព្រះពន្លាខាងត្បូងព្រះមេរុ (រូបលេខ១២០)។

- ម៉ោង៦ល្ងាច៖ កិច្ចថ្វាយក្រយាព្រះស្ងោយ, ថ្វាយស័ង្ខ, ថ្វាយភ្លេង, បក់ផ្លិត, យាមដូចពីពេលថ្ងៃត្រង់ដែរ។

- ម៉ោង៦:៣០យប់៖ កិច្ចព្រះសង្ឃសូត្រព្រះធម្មក្នុងសមសានទាំង៤ ដែលនៅតាមកែងរាជវតិព័ទ្ធជុំវិញតួព្រះមេរុ។



រូបលេខ១១៩៖ ព្រះសង្ឃសូត្រសត្តប្បករណ៍ថ្វាយព្រះបរមសពព្រះករុណាព្រះបាទសម្ដេចព្រះសុរាម្រឹតនៅក្នុងព្រះមេរុ ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១២០៖ ព្រះសង្ឃទេសនានៅព្រះពន្លាខាងត្បូងព្រះមេរុ ក្នុងព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព សម្ដេចព្រះសង្ឃរាជ ជួន ណាត ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។

www.elibraryofcambodia.org

កិច្ចនេះយើងតែងតែឃើញជាដារឿយៗក្នុងពិធីបុណ្យព្រះសពលោកគ្រូចៅអធិការវត្តនានាដែរ (រូបលេខ១២១)។ ជួនកាលទៀតមានសូត្រព្រះធម្មនៅទីតម្កល់ព្រះសពក៏មាន (រូបលេខ១២២)។

- ម៉ោង១២អធ្រាត្រ៖ ធ្វើកិច្ចយាងព្រះអង្គចូលព្រះក្រឡាបន្ទំ។
- ម៉ោង៦ព្រឹក៖ ធ្វើកិច្ចតើនចាកព្រះក្រឡាបន្ទំ មានអ្នកអុជទៀនអុជធូបថ្វាយ សូមយាងព្រះអង្គតើនឡើង, មានព្រាហ្មណ៍ថ្វាយព្រះសុគន្ធវារីស្រពព្រះភ័ក្ត្រ, មានបារគូថ្វាយស័ង្ខ, មានស្ត្រីយំយាម, មានក្រុមភ្លេងលេងថ្វាយ។
- ម៉ោង១០ព្រឹក៖ កិច្ចរាប់បាត្រ ប្រគេនចង្ហាន់ព្រះសង្ឃ។
- ម៉ោង១២ថ្ងៃត្រង់៖ កិច្ចថ្វាយក្រយាព្រះស្ងោយ, ថ្វាយស័ង្ខ, ថ្វាយភ្លេង, បក់ផ្លិត, យំយាម គឺធ្វើដូចថ្ងៃទី១, ទី២, ទី៣... តាមលំដាប់លំដោយរហូត។



រូបលេខ១២១៖ ព្រះសង្ឃសូត្រព្រះធម្មក្នុងសមសាន (ខ្លះហៅថា រោងទិស) បុណ្យរំលាយព្រះសពលោកគ្រូចៅអធិការវត្តបាគង ខេត្ត សៀមរាប ឆ្នាំ១៩៩៣ (រូបថត៖ អាំង ជូលាន)។



រូបលេខ១២២៖ ព្រះសង្ឃសូត្រព្រះធម្មនៅពេលយប់ ក្នុងទីតម្កល់ព្រះសពលោកគ្រូចៅអធិការវត្តអធ្វា ខេត្តសៀមរាប ឆ្នាំ១៩៩៥ (រូបថត៖ អាំង ជូលាន)។

www.elibraryofcambodia.org

# ព្រះរាជពិធីថ្វាយព្រះភ្លើង

"ព្រះភ្លើង" សម្រាប់ថ្វាយព្រះបរមសពត្រូវយកពីព្រះសូរ្យសែង គឺធ្វើកិច្ចយកកែវពង្រីកដាក់បញ្ចាំងកម្ដៅព្រះអាទិត្យលើកម្ទេចស្បូវក្លាំងដែលតម្កល់លើពានឱ្យឆេះឡើង ហើយយកទៀនអុជចម្លងព្រះភ្លើងនោះទៅទៀនធំ ឬចង្កៀងរក្សាទុកគត់មត់មួយអន្លើសិន។ ព្រះភ្លើងដែលយកមកពីព្រះសូរ្យសែងដូច្នោះ មានន័យថាជាព្រះភ្លើងបានមកពីសួគ៌ាលោក ហើយគេហៅថា "ភ្លើងកៃលាស"។ ដូចយើងជ្រាបស្រាប់ហើយថា កៃលាសគឺជាស្ថានព្រះឥសូរ រីឯស្បូវក្លាំងវិញ គឺជារបស់ដែលគេប្រើក្នុងកិច្ចពិធីផ្សេងៗច្រើនយ៉ាងណាស់តាមទំនៀមព្រាហ្មណ៍ពីបុរាណរៀងមក ពិសេសពិធីដែលមានន័យថាធ្វើឱ្យបរិសុទ្ធ។ ព្រះភ្លើងនេះគេអុជចម្លងទៅទៀនឬចង្កៀងមួយទៀត ហែយកទៅកាន់ព្រះមេរុសម្រាប់ថ្វាយព្រះបរមសព។ រីឯព្រះភ្លើងក្នុងចង្កៀងឬទៀនមួយទៀត គេរក្សាទៅក្នុងព្រះរាជវាំងបង្ការទុក ក្រែងមានគ្រាក្រ គេមកអុជតយកព្រះភ្លើងនេះទៀត។

ដល់ថ្ងៃកំណត់ត្រូវធ្វើព្រះរាជពិធីថ្វាយព្រះភ្លើង គេត្រូវយាងព្រះកោដ្ឋដែលតម្កល់លើព្រះមហាបញ្ចាក្នុងព្រះមេរុនោះ រំកិលចុះមកតាមជើងវ៉ែដែលគេតម្លើងឡើងវិញ ហើយសូមយាងព្រះបរមសពផ្ទេរទៅគង់ក្នុងព្រះកោដ្ឋថ្មីធ្វើអំពីឈើរចនាទឹបមាស ហៅថា "ព្រះកោដ្ឋខ្លឹមច័ន្ទន៍" ដោយពុំមានគម្របព្រះកោដ្ឋដូចមកុដគ្របពីលើទៀតទេ គឺគេគ្របសំពត់ល្បើកមាស ឬសំពត់រចនាប្រណីតអ្វីមួយ។ បន្ទាប់មកគេរើព្រះមហាបញ្ចាយកទៅរក្សាទុកមួយអន្លើសិន ហើយតម្លើងជើងថ្កល់បុស្បុករចនាក្បាច់ចាក់ចេក នៅកណ្ដាលព្រះមេរុ និងយាងព្រះកោដ្ឋថ្មី (រូបលេខ១២៣) ទៅតម្កល់ក្នុងបុស្បុកនោះ (រូបលេខ១២៤_១២៦) ត្រៀមថ្វាយព្រះភ្លើងនៅពេលល្ងាច។

www.elibraryofcambodia.org



រូបលេខ១២៣៖ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរត្នសិរីវឌ្ឍនា ថ្វាយបង្គំព្រះបរមសព ព្រះករុណាព្រះនរោត្តម សុរាម្រិត ដែលគេផ្ទេរទៅតម្កល់ក្នុងព្រះកោដ្ឋខ្ទឹមច័ន្ទន៍ រៀបរំកិលឡើងទៅតម្កល់ក្នុងបុស្បុកលើព្រះមេរុ ត្រៀមធ្វើកិច្ចថ្វាយព្រះភ្លើង ឆ្នាំ១៩៦០ (រូបថត៖ ?)។



រូបលេខ១២៤៖ ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះសុរាម្រិត តម្កល់ក្នុងបុស្បុកលើព្រះមេរុ ត្រៀមថ្វាយព្រះភ្លើង ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១២៥៖ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរត្នសិរីវឌ្ឍនា ថ្វាយផ្កាព្រះបរមសពព្រះករុណាព្រះសុរាម្រិត មុនថ្វាយព្រះភ្លើង ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១២៦៖ ព្រះកោដ្ឋព្រះបរមសព សម្ដេចព្រះសង្ឃរាជ ជួន ណាត លើព្រះមេរុ ត្រៀមថ្វាយព្រះភ្លើង ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។

www.elibraryofcambodia.org

លុះដល់វេលាធ្វើកិច្ចថ្វាយព្រះភ្លើងព្រះបរមសព គឺនៅពេលល្ងាចថ្ងៃជិតលិច គេនិមន្តព្រះរាជាគណសង្ឃឡើងព្រះមេរុសូត្រថ្វាយព្រះសត្តប្បករណ៍ បន្ទាប់មកព្រះមហាក្សត្រ ព្រះរាជវង្សានុវង្ស យាងឡើងថ្វាយខ្លឹមច័ន្ទន៍ (រូបលេខ១២៧_១៣០)



រូបលេខ១២៧៖ ខ្លឹមច័ន្ទន៍សម្រាប់ថ្វាយព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនថ្វាយព្រះភ្លើង ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១២៨៖ ខ្លឹមច័ន្ទន៍សម្រាប់ថ្វាយព្រះបរមសព សម្តេចព្រះសង្ឃរាជ ជួន ណាត មុនថ្វាយព្រះភ្លើង ឆ្នាំ ១៩៧១ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១២៩៖ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរត្នសិរីវឌ្ឍនា ថ្វាយខ្លឹមច័ន្ទន៍ព្រះបរមសពព្រះករុណា សុរាម្រឹត មុនថ្វាយព្រះភ្លើង ឆ្នាំ១៩៦០ (រូបថត៖ ?)។



រូបលេខ១៣០៖ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរត្នសិរីវឌ្ឍនា និងព្រះករុណាព្រះនរោត្តម សីហនុ ថ្វាយខ្លឹមច័ន្ទន៍ ថ្វាយផ្កា ព្រះបរមសព ព្រះកុណាព្រះសុរាម្រឹត ឆ្នាំ១៩៦០ (រូបថត៖ ?)។

ព្រមទាំងនាម៉ឺនសពមុខមន្ត្រី និងអគ្គទូតនានា អញ្ជើញឡើងថ្វាយខ្លឹមច័ន្ទន៍ ឬថ្វាយផ្កាខ្លឹមច័ន្ទន៍ ដែលធ្វើពីឈើក្រអូប ឬកំពូលស្លឹកត្នោត (រូបលេខ១៣១_១៣៤)។ រីឯរាជទូត អគ្គទូតនានា និងមន្ត្រីស្ថាប័នអន្តរជាតិផ្សេងៗក៏ឡើងថ្វាយផ្កានេះ ហើយគោរពព្រះបរមសពតាមលំដាប់ដែរ (រូបលេខ១៣៥)។ ចប់កិច្ចថ្វាយខ្លឹមច័ន្ទន៍ ថ្វាយផ្ការួចរាល់ហើយ ព្រះមហាក្សត្រ នាម៉ឺនសពមុខ

www.elibraryofcambodia.org



រូបលេខ១៣១៖ ផ្កាធ្វើពីស្លឹកកំពូលត្នោត សម្រាប់ថ្វាយព្រះបរមសពព្រះករុណាព្រះស៊ីសុវត្ថិ មុនថ្វាយព្រះភ្លើង ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១៣២៖ ផ្កាសម្រាប់ថ្វាយព្រះបរមសពសម្ដេចព្រះសង្ឃរាជ ជួន ណាត មុនថ្វាយព្រះភ្លើង ឆ្នាំ១៩៧១ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១៣៣៖ ព្រះញាតិវង្ស នាម៉ឺនសព្វមុខមន្ត្រីថ្វាយផ្កានិងថ្វាយបង្គំព្រះបរមសពព្រះករុណាព្រះសុរាម្រឹត មុនថ្វាយព្រះភ្លើង ឆ្នាំ១៩៦០ (រូបថត៖ ?)។



រូបលេខ១៣៤៖ នាម៉ឺន សព្វមុខមន្ត្រីថ្វាយផ្កា និងថ្វាយបង្គំព្រះបរមសពសម្ដេចព្រះសង្ឃរាជ កុល ទេស មុនថ្វាយព្រះភ្លើង ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៣៥៖ រាជទូត អគ្គទូតនានា និងមន្ត្រីស្ថាប័នអន្តរជាតិផ្សេងៗ ឡើងគោរពព្រះបរមសពព្រះកុណាព្រះសុរាម្រឹត មុនថ្វាយព្រះភ្លើង ឆ្នាំ១៩៦០ (រូបថត៖ ?)។

មន្ត្រីតូចធំ ខ្ញុំរាជការ និងបណ្ដារាស្ត្រប្រជាទាំងឡាយដែលយាងនិងអញ្ជើញចូលរួមក្នុងព្រះរាជពិធីទាំងមូល ដើបឈរថ្វាយបង្គំព្រះបរមសពតាមចង្វាក់គងបីដង (រូបលេខ១៣៦) ហើយព្រះមហាកក្សត្រយាងថ្វាយព្រះភ្លើងនៅមុខព្រះមេរុ ដោយយកទៀនគុជតពីទៀនធំ ឬចង្កៀងព្រះភ្លើងដែលគេត្បាញទុកជាស្រេចមកនោះ ទៅដុត

www.elibraryofcambodia.org



រូបលេខ១១៣៦៖ ថ្វាយបង្គំព្រះបរមសពព្រះករុណាព្រះស៊ីសុវត្ថិ មុននឹងធ្វើកិច្ចថ្វាយព្រះភ្លើង ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។

ខ្សែកាំជ្រួចឲ្យព្រះភ្លើងរត់បន្តទៅថ្វាយព្រះបរមសព (រូបលេខ១១៣៧_១៣៨)។ បន្ទាប់មកគេទាញរនាំងបាំងភ្លើង មានផ្ទាំងរូបទេពផ្សេងៗឲ្យមកបិទបាំងបុស្បុកតម្កល់ព្រះកោដ្ឋកណ្ដាលព្រះមេរុនោះ កុំឲ្យមើលឃើញ (រូបលេខ១១៣៩)។ វេលាថ្វាយព្រះភ្លើង គឺពួកព្រាហ្មណ៍បារគូថ្វាយស័ង្ខ ហើយ



រូបលេខ១១៣៧៖ ខ្សែនាំព្រះភ្លើងទៅកាន់ព្រះកោដ្ឋព្រះបរមសពព្រះករុណាព្រះស៊ីសុវត្ថិ ពេលថ្វាយព្រះភ្លើង ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១១៣៨៖ ព្រះករុណាព្រះបាទសម្ដេចព្រះមុនីវង្ស ថ្វាយព្រះភ្លើព្រះបរមសពព្រះករុណាព្រះស៊ីសុវត្ថិ ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។



រូបលេខ១១៣៩៖ ក្រុមអ្នករាំង និងអ្នកឯទៀតអង្គុយជុំវិញព្រះមេរុ ក្រោយពីថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះស៊ីសុវត្ថិ ឆ្នាំ១៩២៨ (រូបថត៖ សារមន្ទីរជាតិ)។

មានបាញ់កាំភ្លើង១០១ណាត់, មានស៊ីរ៉ែនរោទិ៍ឡើង, ភ្លេងសព្វបែបយ៉ាងប្រគុំ, ស្គរគង រគាំង តាមវត្តអារាមទូង វាយលាន់ឮតាមម៉ោងកំណត់ ហើយអ្នកនគរទាំងមូលក្រោកឈរគ្រប់ទិស គ្រប់តំបន់ ស្ងៀមស្ងាត់មួយនាទីជាកិច្ចគោរពព្រះវិញ្ញាណក្ខ័ន្ធ។

www.elibraryofcambodia.org

វេលានោះ ព្រះសង្ឃដែលចេះធម៌ព្រះអភិធម្ម ឬហៅថា "ធម៌ធ្មេច" ឬមួយ "ធម៌ក្នុង" គង់ក្នុងសមសានទាំង៤ទិសនៅតាមកែងរាជវតិនៃព្រះមេរុ តាំងសមាធិផ្ចង់ស្មារតីតម្រង់ផ្លូវព្រះវិញ្ញាណក្ខ័ន្ធនៃព្រះបរមសព ឲ្យយាងឆ្ពោះទៅកាន់ព្រះសុគតិភព សោយព្រះបរមសុខឰដ៏សួគ៌ាល័យ។ បន្ទាប់មកព្រះមហាក្សត្រ និងព្រះញាតិវង្សយាងចូលព្រះបរមរាជវាំង ព្រមទាំងនាម៉ឺនធំៗ និងអង្គទូតនានាអញ្ជើញត្រឡប់ទៅវិញ។ បន្តមក នៅលើព្រះពន្លាមានព្រះញាតិវង្សខ្លះ និងអ្នកស្ម័គ្រចិត្តតាមចំនួនកំណត់ ធ្វើកិច្ចបួសមុខព្រះភ្លើងថ្វាយព្រះរាជកុសលផង ហើយគេនិមន្តព្រះសង្ឃសម្តែងធម៌ទេសនាមុខព្រះភ្លើងនៅលើព្រះពន្លា រីឯព្រះភ្លើងថ្វាយព្រះបរមសពហើយនោះ ត្រូវទុករយៈពេលមួយយប់ពេញ។

# ពិធីរើសព្រះបរមអដ្ឋិ និងជន្លៃព្រះអង្គារនៅទន្លេ

លុះព្រឹកឡើងបន្ទាប់ពីថ្ងៃថ្វាយព្រះភ្លើង គេធ្វើពិធីរើសព្រះបរមអដ្ឋិ និងធ្វើកិច្ចជាបន្តបន្ទាប់តាមលំដាប់លំដោយប៉ុន្មានថ្ងៃទៀត។ នៅវេលាព្រឹក ព្រះមហាក្សត្រនិងព្រះរាជវង្សានុវង្ស ព្រមទាំងនាម៉ឺនសពមុខមន្ត្រីយាងនិងអញ្ជើញមកដល់ព្រះមេរុ ហើយនិមន្តព្រះសង្ឃ៨អង្គឡើងថ្វាយព្រះពរទឹក និងបារគូថ្វាយស័ង្ខ បន្ទាប់មកនិមន្តព្រះសង្ឃ៤អង្គធ្វើកិច្ចប្រែព្រះរូប និងសូត្រធម៌ក្តុំព្រះធាតុថ្វាយ *(រូបលេខ ១៤០)* ស្រេចហើយ ព្រះមហាក្សត្រប្រគេនទេយ្យទានពាអម្រែងទៅព្រះសង្ឃដែលនិមន្តធ្វើកិច្ចនោះ។ បន្តមកទៀតបារគូធ្វើកិច្ចបង្វិលពពិលឧត្តរព័ត៌១៩ឬ២១ជុំ *(រូបលេខ១៤១)* ហើយយាងព្រះមហាកក្សត្រ និងព្រះញាតិវង្សរើសព្រះបរមអដ្ឋិ *(រូបលេខ១៤២)* និងថ្វាយទឹកកុណ្ឌីស្រពព្រះអដ្ឋិ *(រូបលេខ១៤៣_១៤៤)*។ ព្រះបរមអដ្ឋិ

www.elibraryofcambodia.org



រូបលេខ១៤០៖ ព្រះសង្ឃថ្វាយព្រះពរទឹករូចប្រែព្រះរូបព្រះអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៤១៖ ក្រុមបារគូធ្វើកិច្ចបង្វិលពពិលថ្វាយព្រះបរមអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៤២៖ រើសព្រះបរមអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៤៣៖ ទឹកកុណ្ឌី សម្រាប់ថ្វាយព្រះពរទឹកព្រះបរមអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៤៤៖ ថ្វាយព្រះពរទឹក ព្រះបរមអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៤៥៖ ព្រះករុណាព្រះនរោត្តម សីហនុ យាងព្រះបរមអដ្ឋិព្រះករុណាព្រះសុរាម្រឹត ចុះចាកពីព្រះមេរុ, ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។

ដែលរើសដាក់កញ្ច្រែងមាសហើយ តម្កល់លើពានយាងចុះចាកព្រះមេរុ (រូបលេខ ១៤៥) និងដង្ហែទៅកាន់ព្រះពន្លាសម្រាប់ព្រះមហាក្សត្រនៅខាងត្បូងព្រះមេរុ (រូប លេខ១៤៦) រួចហើយយាងឡើងតម្កល់លើព្រះបញ្ញានៅក្នុងព្រះពន្លានោះមួយអន្លើ

www.elibraryofcambodia.org

សិន (រូបលេខ១៤៧)។ កិច្ចជាបន្ទាប់មកទៀតនោះ គឺគេប្រមូលព្រះអង្គារ គឺផេះនិងឆ្អឹងដាក់ក្នុងថវិកាពណ៌ប្រាក់ (ថង់កំណាត់សំពត់ពណ៌ប្រាក់) ចំនួន៣ តម្កល់លើរទេះស្នែងហែជាក្បួនទៅបំផ្លែងនៅទឹកទន្លេមុខព្រះបរមរាជវាំង។

ចំណែកឯជើងថ្កល់បុស្បុកសម្រាប់ថ្វាយព្រះភ្លើងនៅក្នុងព្រះមេរុនោះត្រូវរើយកចេញ ហើយតម្លើងព្រះមហាបញ្ញាឡើងវិញម្ដងទៀត ត្រៀមតម្កល់កោដ្ឋព្រះបរមអដ្ឋិនាពេលរសៀលដើម្បីធ្វើកិច្ចពិធីជាបន្តបន្ទាប់ទៀត។



រូបលេខ១៤៦៖ ហែព្រះបរមអដ្ឋិព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សុរាម្រិត ចេញពីព្រះមេរុទៅកាន់ព្រះពន្លា, ឆ្នាំ១៩៦០ (រូបថត៖?)។



រូបលេខ១៤៧៖ តម្កល់ព្រះបរមអដ្ឋិសម្ដេចព្រះសង្ឃរាជ ភុល ទេស លើព្រះបញ្ញា ក្នុងព្រះពន្លាទុកឲ្យស្រស់ល្អ, ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។

## កិច្ចយាងព្រះបរមអដ្ឋិគង់ក្នុងព្រះកោដ្ឋពេជ្រ

ក្រោយពីរើសព្រះបរមអដ្ឋិ និងយាងមកតម្កល់លើព្រះពន្លា ព្រមទាំងទុកឲ្យស្អាតល្អហើយ លុះដល់វេលារសៀលត្រូវធ្វើកិច្ចយាងព្រះបរមអដ្ឋិគង់ក្នុងព្រះកោដ្ឋពេជ្រ (សាងអំពីមាស)។ ពេលនោះព្រះមហាក្សត្រ និងព្រះញាតិវង្សយាងមកកាន់ព្រះពន្លា ព្រមទាំងនាម៉ឺនមន្ត្រីព្រះបរមរាជវាំងអមដង្ហែផង។ គេលើកព្រះអដ្ឋិផ្ទាល់

www.elibraryofcambodia.org

ព្រះហស្តម្តងមួយៗដាក់ក្នុងព្រះកោដ្ឋពេជ្រ (*រូបលេខ១៤៨_១៤៩*) រួចរាល់ហើយ ក្រុមព្រាហ្មណ៍ចារគូរៀបចំតម្កល់ព្រះកោដ្ឋពេជ្រលើពានពត្រួត គឺពានធំនៅខាងក្រោម និងពានតូចជាបន្តបន្ទាប់ទៅលើ។ គេយកអំបោះសចងស្រាក់ព្រះកោដ្ឋនិងពានទាំងពត្រួតឲ្យជាប់មាំនឹងគ្នា (*រូបលេខ១៥០*)។



*រូបលេខ១៤៨៖ យាងព្រះបរមអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស តង់ក្នុងព្រះកោដ្ឋពេជ្រ ឆ្នាំ១៩៦០ (រូបថត៖* Madeleine Giteau )។



*រូបលេខ១៤៩៖ យាងព្រះបរមអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស តង់ក្នុងព្រះកោដ្ឋពេជ្រ ឆ្នាំ១៩៦០ (រូបថត៖* Madeleine Giteau )។



*រូបលេខ១៥០៖ ព្រះបរមអដ្ឋិនៅក្នុងព្រះកោដ្ឋពេជ្រ តែងដាក់តម្កល់លើពានពត្រួត (រូបថត៖* Madeleine Giteau )។

# តម្កល់កោដ្ឋព្រះបរមអដ្ឋិលើមហាបញ្ជាក្នុងព្រះមេរុ

ក្រោយពីយាងព្រះបរមអដ្ឋិតង់ក្នុងព្រះកោដ្ឋពេជ្រ តម្កល់លើពានទាំងពត្រួតហើយ គេយាងក្បូត្រាមួយអង្គកាន់ទ្រពានព្រះកោដ្ឋពេជ្រនោះ ហែចេញពីព្រះពន្លាទៅកាន់ព្រះមេរុ រួចឡើងតង់លើរាំងទេចក្តល់លើជើងរ៉ៃ (*រូបលេខ១៥១*) គេរំកិលឡើងទៅដល់លើ និងដាក់ពានព្រះបរមអដ្ឋិតម្កល់លើព្រះមហាបញ្ជាក្នុងព្រះមេរុឡើងវិញ (*រូបលេខ១៥២*)។ ព្រះមហាបញ្ជាសម្រាប់តម្កល់ព្រះកោដ្ឋនោះ កាលពីព្រះ

www.elibraryofcambodia.org



រូបលេខ១៥១៖ រំកិលព្រះកោដ្ឋព្រះបរមអដ្ឋិឡើងទៅតម្កល់លើព្រះមហាបញ្ចាក្នុងព្រះមេរុ (រូបថត៖ Madeleine Giteau)។



រូបលេខ១៥២៖ តម្កល់ព្រះកោដ្ឋព្រះបរមអដ្ឋិលើព្រះមហាបញ្ចាក្នុងព្រះមេរុ (រូបថត៖ Madeleine Giteau)។

រាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម គេធ្វើធំដុំណាស់ ហើយមានកម្ពស់ខ្ពស់ទៀតផង (រូបលេខ១៥៣)។ តម្កល់កោដ្ឋព្រះអដ្ឋិរួចរាល់ហើយ គេដោះយកជើងរ៉ៃទៅរក្សាទុកមួយអន្លើសិន ហើយក្រុមបារគូអញ្ជើញឡើងព្រះមេរុថ្វាយស័ង្ខ។ បន្ទាប់មកទៀត គេនិមន្តព្រះសង្ឃ៣២អង្គចម្រើនព្រះបរិត្តព្រះពុទ្ធមន្ត ថ្វាយសត្តប្បករណ៍ និងសម្តែងធម៌ទេសនាបឋមត្រាស់ រួចធ្វើកិច្ចអភិសេកព្រះពុទ្ធរូបក្នុងព្រះមេរុនាយប់នោះ។

នារាត្រីតម្កល់ព្រះបរមសពនិងព្រះអដ្ឋិនៅក្នុងព្រះមេរុនេះ តាមទំនៀមមកមានសម្តែងល្ខោនស្បែកធំ និងល្ខោនខោលជាដើម (លេងរឿងរាមកេរ្តិ៍) ព្រមទាំងល្បែងរបាំផ្សេងៗ និងអុជកាំជ្រួច ភ្លៃទៀន ជាឱឡារិកអធិកអធមថ្វាយព្រះរាជកុសលផង។ ប្រពៃណីបែបនេះមានជាទូទៅស្ទើរគ្រប់តំបន់ក្នុងប្រទេសកម្ពុជា មិនថាបុណ្យរំលាយសពសម្រាប់រាស្ត្រសាមញ្ញ ឬព្រះសង្ឃតូចធំ ឬព្រះញាតិវង្ស និងព្រះមហាក្សត្រឡើយ គឺឲ្យតែបុណ្យណាមានភាពធំដុំ ច្រើនមានល្បែងរបាំ ល្ខោនផ្សេងៗ

www.elibraryofcambodia.org

នោះ រួមជាមួយកិច្ចធ្វើបុណ្យ ធ្វើកុសល បំពេញទានឧទ្ទិសមគ្គផលទៅដល់អ្នក ដែលចែកស្ថាននោះឯងហើយ។



រូបលេខ១៥៣៖ ព្រះកោដ្ឋ ព្រះបរមអដ្ឋិព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម តម្កល់លើព្រះមហាបញ្ជាក្នុង ព្រះមេរុ ឆ្នាំ១៩០៦ (រូបថត៖ Ahémard Leclère )។

# ពិធីហែព្រះបរមអដ្ឋិចូលព្រះបរមរាជវាំង

ក្រោយពីតម្កល់កោដ្ឋព្រះបរមអដ្ឋិលើព្រះមហាបញ្ជាក្នុងព្រះមេរុ២_៣ យប់មក លុះព្រឹកថ្ងៃចុងក្រោយ ព្រះមហាក្សត្រ, ព្រះរាជវង្សានុវង្ស, នាម៉ឺន មន្ត្រីតូចធំ ខ្ញុំរាជការយាងនិងអញ្ជើញមកកាន់ទីព្រះមេរុ។ គេក៏និមន្តព្រះសង្ឃសូត្រថ្វាយសត្តប្បករណ៍រួចរាល់ហើយ គេចាត់ក្សត្រាមួយអង្គឡើងទៅសូមយាងកោដ្ឋព្រះបរមអដ្ឋិរំកិលចុះចាកពីព្រះមហាបញ្ជាក្នុងព្រះមេរុ (រូបលេខ១៥៤_១៥៥)។ លុះរំកិលកោដ្ឋព្រះបរមអដ្ឋិចុះមកដល់ក្រោមហើយ (រូបលេខ១៥៦) គេយាងព្រះកោដ្ឋតម្កល់លើគ្រែស្នែងធំ ដែលគេរៀបរង់ចាំស្រេចនៅនឹងមុខជណ្តើរខាងកើតព្រះមេរុ (រូបលេខ១៥៧)។ បន្ទាប់មកហែជាក្បួន មានភ្លេង, មានក្លស់, អភិរម្យ, បាំងសែង, សែនត្វិន, ចាមរ, បៃមន់, ភូតាន។ល។ មានក្រុមព្រាហ្មណ៍បារគូផ្លុំស័ង្ខបន្លឺឡើង ហើយក៏ហែចូលទៅកាន់ព្រះបរមរាជវាំង ដោយមានព្រះមហាក្សត្រ និងព្រះញាតិវង្ស ព្រមទាំងនាម៉ឺនមន្ត្រីធំៗ យាងដើរដង្ហែតាមក្រោយចូលទៅជាមួយផង (រូបលេខ១៥៨)។

www.elibraryofcambodia.org



រូបលេខ១៥៤៖ រំកិលព្រះកោដ្ឋព្រះបរមអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស ចុះពីព្រះមហាបញ្ញា ក្នុងព្រះមេរុ, ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៥៥៖ រំកិលព្រះកោដ្ឋព្រះបរមអដ្ឋិសម្តេចព្រះសង្ឃរាជ កុល ទេស ចុះពីព្រះមហាបញ្ញា ក្នុងព្រះមេរុ, ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។



រូបលេខ១៥៦៖ រំកិលព្រះកោដ្ឋព្រះបរមអដ្ឋិសម្តេចព្រះវត្ថរាជធីតា ពិន្ទុភា សុតារ៉េត ចុះពីព្រះមេរុ, ឆ្នាំ១៩៦៥ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១៥៧៖ តម្កល់ព្រះកោដ្ឋព្រះអដ្ឋិសម្តេចព្រះវត្ថរាជធីតា ពិន្ទុភា សុតារ៉េត លើគ្រែស្នែង ឆ្នាំ១៩៦៥ (រូបថត៖ EFEO, Madeleine Giteau )។



រូបលេខ១៥៨៖ ក្បួនហែព្រះកោដ្ឋព្រះបរមអដ្ឋិព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត ចេញពីទីព្រះមេរុយាងចូលព្រះបរមរាជវាំង, ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។

www.elibraryofcambodia.org

លុះចូលដល់ព្រះបរមរាជវាំងហើយ ក៏ឡើងទៅព្រះទីនាំងទេវាវិនិច្ឆ័យ រួចព្រះមហាក្សត្រយាងលើកពានព្រះកោដ្ឋព្រះបរមអដ្ឋិទៅតម្កល់លើព្រះបញ្ញានៅខាងមុខព្រះមហាស្វេតច្ឆ័ត្រ (រូបលេខ១៥៩) និងក្រុមបារគូថ្វាយស័ង្ខ បន្ទាប់មក ព្រះសង្ឃសូត្រថ្វាយព្រះសត្តប្បករណ៍។ ចុងបញ្ចប់ នាម៉ឺនសព្វមុខមន្ត្រីថ្វាយបង្គំលាតាមចង្វាក់គង។

ឯកិច្ចពិធីជាបន្តបន្ទាប់នៅក្នុងព្រះបរមរាជវាំងទៅទៀតនោះ គឺធ្វើដោយក្រុមព្រះញាតិវង្ស និងនាម៉ឺនសព្វមុខមន្ត្រីព្រះបរមរាជវាំង គឺយាងព្រះកោដ្ឋព្រះបរមអដ្ឋិតម្កល់ក្នុងហោព្រះអដ្ឋិ នៅនាព្រះទីនាំងទេវាវិនិច្ឆ័យ (រូបលេខ១៦០) ឬនៅទីដ៏ប្រសើរដែលគ្រោងទុកមកតាមសមគួរ។ ទីបញ្ចប់ គឺយាងព្រះកោដ្ឋព្រះបរមអដ្ឋិទៅតម្កល់ក្នុងព្រះមហាចេតិយដ៏ប្រសើរណាមួយ (រូបលេខ១៦១_១៦២) ជាកិច្ចបញ្ចប់។



រូបលេខ១៥៩៖ ព្រះករុណាព្រះនរោត្តម សីហនុ លើកពានព្រះកោដ្ឋព្រះបរមអដ្ឋិព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សុរាម្រឹត តម្កល់លើព្រះបញ្ញានៅមុខព្រះមហាស្វេតច្ឆ័ត្រ ឆ្នាំ១៩៦០ (រូបថត៖ Archives R. Viollet)។



រូបលេខ១៦០៖ តម្កល់ព្រះកោដ្ឋព្រះបរមអដ្ឋិព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សុរាម្រឹត លើព្រះបញ្ញាក្នុងព្រះបរមរាជវាំង ឆ្នាំ១៩៦០ (រូបថត៖ ?)។



រូបលេខ១៦១៖ ព្រះកោដ្ឋព្រះបរមអដ្ឋិសម្ដេចព្រះសង្ឃរាជ កុល ទេស តម្កល់លើព្រះបញ្ញាត្រៀមហែឡើងតម្កល់ក្នុងព្រះចេតិយ ឆ្នាំ១៩៦០ (រូបថត៖ Madeleine Giteau )។

www.elibraryofcambodia.org



*រូបលេខ១៦២៖ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរត្នសិរីវឌ្ឍនា និងព្រះញាតិវង្ស យាងចុះចាកពីព្រះចេតិយ បន្ទាប់ពីតម្កល់ព្រះកោដ្ឋព្រះបរមអដ្ឋិព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត ក្នុងព្រះចេតិយក្បែរព្រះវិហារព្រះកែវមរកតនៃព្រះបរមរាជវាំង ឆ្នាំ១៩៦០ (រូបថត៖ ?)។*

# អំពីឯកសណ្ឋាន

- ព្រះមហាក្សត្រ និងព្រះញាតិវង្សដែលជាក្សត្រា ទ្រង់សំពត់ចងក្បិន, អាវកុតកត្រង់, ស្រោមជើង, ទ្រនាប់ជើង សុទ្ធតែពណ៌ស និងប៉ាន់ដៃខ្មៅ។

- ព្រះមហាក្សត្រី និងព្រះញាតិវង្សជាក្សត្រី ទ្រង់សំពត់សម្លុយ ឬចងក្បិន, អាវដៃខ្លី ឬវែង, កន្សែងពាទា, ទ្រនាប់ជើង សុទ្ធតែពណ៌ស (រូបលេខ១៦៣)។

- ក្រុមព្រាហ្មណ៍បារគូ ស្លៀកសំពត់ចងក្បិន, អាវកុតកត្រង់, អាវផាយ, ស្រោមជើង ទ្រនាប់ជើង សុទ្ធតែពណ៌ស។

- ក្រុមអមព្រះកោដ្ឋ, ក្រុមកាន់ផ្កាឈូក, អ្នកកាន់សំពត់ទូជាដើម ស្លៀកសំពត់ចងក្បិន, អាវកុតកត្រង់, អាវផាយ, ពាក់មួកលំផក, ស្រោមជើង, ទ្រនាប់ជើង សុទ្ធតែពណ៌ស និងប៉ាន់ដៃខ្មៅ។

- ក្រុមកាន់គ្រឿងហែ ស្លៀកសំពត់ចងក្បិន, អាវកុតកត្រង់, ពាក់មួកប្រពាត,

www.elibraryofcambodia.org

ស្រោមជើង, ទ្រនាប់ជើង សុទ្ធតែពណ៌ស និងប៉ាន់ដៃខ្មៅ (រូបលេខ១១៦៤)។

- ក្រុមអ្នកភ្លេងពិណពាទ្យនិងភ្លេងក្លងឆ្នៈ ឬក្លងខែក ស្លៀកសំពត់ចងក្បិន, អាវកុតកត្រង់, ស្រោមជើង, ទ្រនាប់ជើង សុទ្ធតែពណ៌ស និងប៉ាន់ដៃខ្មៅ (រូបលេខ១១៦៥))។ ឯក្រុមអ្នកភ្លេងខ្មែរច្រើនស្លៀកសំពត់ចងក្បិន ពាក់អាវកម្ពុលដៃខ្លី ស្រោមជើង និងទ្រនាប់ជើងសុទ្ធតែពណ៌ស។

- នាម៉ឺន សព្វមុខមន្ត្រី ស្លៀកសំពត់ចងក្បិន, អាវកុតកត្រង់, ស្រោមជើង, ទ្រនាប់ជើងសុទ្ធតែពណ៌ស និងប៉ាន់ដៃខ្មៅ។



រូបលេខ១១៦៣៖ ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសុមៈនារីរត្ន សិរីវឌ្ឍនា, ក្សត្រា, ក្សត្រី និងនាម៉ឺនតូចធំ ក្នុងព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសពព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត ឆ្នាំ១៩៦០ (រូបថត៖ William and Sarah Thomas Collection: http://arrow.monash.edu.au/hdl/1959)។



រូបលេខ១១៦៤៖ ក្រុមកាន់គ្រឿងហែ (រូបថត៖ ?)។



រូបលេខ១១៦៥៖ ក្រុមអ្នកភ្លេង (រូបថត៖ ?)។

www.elibraryofcambodia.org

# ជំពូក២

# ព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព
# ព្រះករុណាព្រះបាទសម្ដេច
# ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ
# (ព្រះបរមរតនកោដ្ឋ)

www.elibraryofcambodia.org

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ទ្រង់ដាក់ព្រះជន្មសង្ខារយាងចូលព្រះទិវង្គត នាថ្ងៃច័ន្ទ ១៥រោច ខែភទ្របទ (ភ្ជុំបិណ្ឌ) ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី១៥ ខែតុលា គ.ស.២០១២ វេលាម៉ោង១និង២០នាទីរំលងអធ្រាត្រ ក្នុងជន្មាយុ៩០ព្រះវស្សា នៅឯមន្ទីរពេទ្យក្រុងប៉េកាំង ប្រទេសចិន។

ដំណឹងដ៏សោកសៅជាទីបំផុត រកអ្វីប្រៀបផ្ទឹមពុំបាននេះ ធ្វើឱ្យមនុស្សម្នាទូទាំងព្រះនគរមានសេចក្តីរន្ធត់ស្លុតចិត្តឥតឧបមា មិនថាចាស់ មិនថាក្មេង មានសេចក្តីក្រៀមក្រំសោកសង្រេងជាពន់ពេក។ ពិតមែនតែព្រះបរមសពតម្កល់នៅឯមន្ទីរពេទ្យក្រុងប៉េកាំងត្រៀមរៀបចំយាងដង្ហែមកកាន់ព្រះរាជាណាចក្រកម្ពុជាពីរថ្ងៃក្រោយមកទៀតមែន តែនៅឯព្រះបរមរាជវាំង រាជធានីភ្នំពេញឯណោះវិញ មានរាស្ត្រប្រជាមនុស្សម្នាទៅកាន់មុខព្រះបរមរាជវាំងហូរហែដោយក្តីក្តុកក្តួលយ៉ាងក្រៃលែង។ នៅថ្ងៃច័ន្ទ ទី១៥ ខែតុលា ឆ្នាំ២០១២ ម៉ោង៥ល្ងាច មានមនុស្សទៅជួបជុំគ្នាសូត្រធម៌ ថ្វាយបង្គំនៅចំពីមុខខ្លោងទ្វារជ័យនៃព្រះបរមរាជវាំង (រូបលេខ១៦៦)។ លុះចាប់ពីព្រឹកឡើងថ្ងៃអង្គារ ១កើត ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦



រូបលេខ១៦៦៖ មនុស្សម្នាជាប្រជារាស្ត្រខ្លះនាំគ្នាទៅអង្គុយសូត្រធម៌នៅមុខខ្លោងទ្វារជ័យនៃព្រះបរមរាជវាំង នាល្ងាចថ្ងៃច័ន្ទ ១៥រោច ខែភទ្របទ (ថ្ងៃភ្ជុំបិណ្ឌ) ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី ១៥ ខែតុលា គ.ស.២០១២ ឧទ្ទិសថ្វាយព្រះមហាវីរក្សត្រ បន្ទាប់ពីដឹងថាព្រះអង្គសោយទិវង្គតនៅមន្ទីរពេទ្យក្រុងប៉េកាំង។

www.elibraryofcambodia.org

ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១២ រហូតមក មានមនុស្សគ្រប់ទិសទី ក្មេង ចាស់ ស្រី ប្រុស អញ្ជើញទៅមុខព្រះបរមរាជវាំង អុជធូប អុជទៀន ថ្វាយផ្កា សូត្រធម៌ បន្ត បន្ទាប់គ្នាច្រើនឡើងៗទាំងថ្ងៃទាំងយប់ឥតដាច់ (រូបលេខ១៦៧_១៦៨)។



រូបលេខ១៦៧៖ ប្រជារាស្ត្រមកពីទីផ្សេងៗអុជធូប អុជទៀន អង្គុយសូត្រធម៌នៅមុខប្រាសាទច័ន្ទឆាយានៃព្រះបរមរាជវាំង។



រូបលេខ១៦៨៖ មនុស្សម្នាទៅថ្វាយផ្កា អង្គុយសូត្រធម៌ឧទ្ទិសថ្វាយព្រះមហាវីរក្សត្រ ក្នុងពេលដែលព្រះបរមសពតម្កល់ឯមន្ទីរពេទ្យក្រុងប៉េកាំងនៅឡើយ។

នៅព្រឹកថ្ងៃពុធ ២កើត ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី១៧ ខែតុលា គ.ស.២០១២ ក្រោយពីថ្នាក់ដឹកនាំសំខាន់ៗរបស់ប្រទេសចិន ព្រមទាំងគ្រូពេទ្យធំៗ អញ្ជើញទៅធ្វើកិច្ចគោរពព្រះបរមសពព្រះមហាវីរក្សត្រនៅឯមន្ទីរពេទ្យក្រុងប៉េកាំងរួច ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី និងសម្តេចព្រះវររាជមាតា ព្រមទាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី បានយាងនិងអញ្ជើញថ្វាយបង្គំ និងសូមយាងព្រះបរមសពនិវត្តមកកាន់មាតុភូមិកម្ពុជា។

នៅរសៀលថ្ងៃពុធ ទី១៧ ខែតុលា ឆ្នាំ២០១២ ព្រះទីនាំងហង្សា (យន្តហោះ)

www.elibraryofcambodia.org

តម្កល់ព្រះបរមសពព្រះមហាវីរក្សត្រ  យាងមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយមានព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ជាអម្ចាស់ជីវិតលើត្បូង, ព្រះមហាក្សត្រីព្រះវររាជមាតា, សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, ព្រះសង្ឃពអង្គ (ដឹកនាំដោយសម្តេចព្រះវនរត ណាយ ច្រឹក) ព្រមទាំងតំណាងថ្នាក់ដឹកនាំប្រទេសចិនជាច្រើនរូប យាងនិងអញ្ជើញរួមដង្ហែព្រះបរមសពមកជាមួយផង។

នៅឯព្រលានយន្តហោះភ្នំពេញមានព្រះរាជវង្សានុវង្ស, ថ្នាក់ដឹកនាំនិងសមាជិកព្រឹទ្ធសភា, រដ្ឋសភា, រាជរដ្ឋាភិបាល, តុលាការ ព្រមដោយនាម៉ឺនសព្វមុខមន្ត្រីគ្រប់ជាន់ថ្នាក់ទាំងអស់ យាងនិងអញ្ជើញទទួល និងគោរពព្រះបរមសពយ៉ាងស្ងៀមស្ងាត់ ដែលពោរពេញដោយក្តីក្រៀមក្រំ ក្តុកក្តួល រំជួលចិត្តឥតឧបមារៀង។ខ្លួន។ នៅអមសងខាងផ្លូវចាប់ពីព្រលានយន្តហោះមកដល់ព្រះបរមរាជវាំង មានព្រះសង្ឃ និងមនុស្សម្នាដ៏ច្រើនណែនណាន់តាន់តាប់ ដែលគេស្មានថាប្រហែលជាយ៉ាងហោចណាស់ក៏ជាងមួយលាននាក់ដែរ អញ្ជើញមកពីគ្រប់ទិសទី ទាំងចាស់ ទាំងក្មេងស្រី ប្រុស ទាំងអ្នកជរា ពិការយ៉ាងណា ក៏ខិតខំអញ្ជើញមករង់ចាំព្រះបរមសពព្រះមហាវីរក្សត្ររបស់ខ្លួនដោយក្តីសោកសៅរកទីបំផុតគ្មាន (រូបលេខ១៦៩_១៧០)។ គ្រាដែលព្រះទីនាំងរាជហង្សតម្កល់ព្រះបរមសពយាងរំកិលមកដល់ចំណុចត្រង់ណាត្រង់កន្លែងនោះលាន់ឮសម្លេងយំសោកដោយក្តីសង្វេគ និងអ្នកខ្លះយំខ្សឹកខ្សួលអួលអាក់ ឯអ្នកខ្លះទៀតក៏មានទឹកភ្នែករលីងរលោង ឬទឹកមុខស្រពាប់ស្រពោន ទំនងជាអារម្មណ៍រំពឹងគិតនឹកស្តាយស្រណោះអាឡោះអាល័យព្រះមហាវីរក្សត្រដ៏ជាទីគោរព ស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុតក្នុងដួងចិត្តរបស់ខ្លួន។

www.elibraryofcambodia.org



រូបលេខ១៦៩៖ ប្រជាពលរដ្ឋមកពីគ្រប់ទិសទី រង់ចាំហ្វូវហែទទួលព្រះបរមសពទៅរាជធានីភ្នំពេញ ទាវសៀលថ្ងៃពុធ ២កើត ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី១៧ ខែតុលា គ.ស.២០១២។



រូបលេខ១៧០៖ មនុស្សម្នាទាំងឡាយអង្គុយលត់ជង្គង់ លើកដៃប្រណម្យដោយក្ដីក្រៀមក្រំ និងសោកសង្រេង ពេលដែលក្បួនហែព្រះបរមសពយាងមកដល់។

ពេលក្បួនហែព្រះបរមសពព្រះមហាវីរក្សត្រវិកិលទៅដល់ត្រង់កន្លែងណាដែលមានក្រុមព្រះសង្ឃ ត្រង់នោះក៏លាន់ឮសម្លេងព្រះធម៌បង្សុកូល ដែលព្រះសង្ឃស្វាធ្យាយឡើងដោយក្ដីសង្វេគក្រៃលែង។

ក្បួនដង្ហែព្រះបរមសពពីព្រលានយន្តហោះមកព្រះបរមរាជវាំង គឺមានរថយន្តតម្កល់ព្រះឆាយាល័ក្ខណ៍ធំមួយ (រូបលេខ១៧១)។ ខាងក្រោយនោះមានរថយន្តក្រុមភ្លេងពិណពាទ្យ។ ព្រះទីនាំងរាជសីហ៍ សម្រាប់សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ (មហានិកាយ និងធម្មយុត្តិកនិកាយ) គង់ទាំមុខ (រូបលេខ១៧២)។ បន្ទាប់មកជាព្រះទីនាំងរូបរាជហង្ស តម្កល់ព្រះមញ្ជូសា (មឈូស) ព្រះបរមសពព្រះមហាវីរក្សត្រ (រូបលេខ១៧៣)។ ការតម្កល់ព្រះបរមសពលើព្រះទីនាំងរូបរាជហង្សដូច្នេះ គឺក្នុងន័យថា ខ្ពង់ខ្ពស់ ហាក់ហោះ ហាក់អណ្ដែតក្នុងអាកាស ដ្បិតហង្សជាសត្វក្នុងទេពកថា ជាសត្វនៅឯសួគ៌ាល័យ ជាយានជំនិះនៃព្រះព្រហ្មជាដើម ដូចបានពោលរួចមកហើយ។ រីឯព្រះទីនាំងរូបនាគរាជ ដឹកព្រះរាជាគណៈសង្ឃ (រូបលេខ១៧៤) នៅ

www.elibraryofcambodia.org



រូបលេខ១៧១៖ រថយន្តតម្កល់ព្រះឆាយាល័ក្ខណ៍ព្រះមហាវីរក្សត្រក្នុងក្បួនហែព្រះបរមសពមកពីព្រលានយន្តហោះ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២។



រូបលេខ១៧២៖ ព្រះទីនាំងរាជសីហ៍ សម្រាប់សម្តេចព្រះសង្ឃរាជគង់ហែនាំមុខព្រះបរមសព។



រូបលេខ១៧៣៖ ព្រះទីនាំងរាជហង្ស តម្កល់ព្រះបរមសពព្រះមហាវីរក្សត្រ។



រូបលេខ១៧៤៖ ព្រះទីនាំងនាគរាជ សម្រាប់ព្រះរាជាគណៈសង្ឃគង់ហែពីក្រោយព្រះបរមសព។

www.elibraryofcambodia.org

ខាងក្រោយបន្ទាប់ពីព្រះទីនាំងព្រះបរមសព។ បន្តទៅខាងក្រោយទៀតជាព្រះទីនាំងរថយន្តព្រះករុណាជាអម្ចាស់ និងសម្តេចព្រះមហាក្សត្រីព្រះវររាជមាតា ព្រមទាំងរថយន្តព្រះរាជវង្សានុវង្ស, សម្តេចប្រធានរដ្ឋសភា, សម្តេចនាយករដ្ឋមន្ត្រី, សម្តេចចៅហ្វាវាំង, នាម៉ឺនសព្វមុខមន្ត្រី និងគណៈប្រតិភូប្រទេសចិន រួមទាំងរាជទូត អគ្គទូតនានា។ នៅមុខព្រះបរមរាជវាំងឯណោះមានមនុស្សម្នាកកកុញ ឈរវង់ចាំក្បួនហែព្រះបរមសពមកដល់ (រូបលេខ១៧៥)។ បន្ទាប់មកមានមនុស្សច្រើនមីរដេរដាសយកផ្កាភ្ញី ធូបទៀន មកធ្វើសក្ការបូជាពេញទាំងទីលានខាងមុខប្រាសាទច័ន្ទឆាយា (រូបលេខ១៧៦)។



រូបលេខ១៧៥៖ ក្បួនហែព្រះបរមសពមកដល់មុខព្រះរាជវាំង មានប្រជារាស្ត្រកកកុញរង់ចាំទទួល។



រូបលេខ១៧៦៖ សិស្ស និស្សិត និងប្រជាពលរដ្ឋមកពីគ្រប់ទិសទីនៅមុខព្រះបរមរាជវាំង។

ព្រះរាជរដ្ឋាភិបាលប្រកាសកាន់ទុក្ខទូទាំងប្រទេសរយៈពេល៧ថ្ងៃ (ដំណាក់កាលទី១)។ ព្រះសង្ឃ, នាម៉ឺនសព្វមុខមន្ត្រី, រាជការគ្រប់ជាន់ថ្នាក់ និងប្រជារាស្ត្រទូទៅខ្ទាស់បូរពណ៌ខ្មៅ ឬពណ៌សនៅលើអាវខាងមុខផ្នែកខាងឆ្វេង ជាសញ្ញាបញ្ជាក់ពីការកាន់ទុក្ខព្រះមហាវីរក្សត្រដែលព្រះអង្គសោយទិវង្គត។ នៅតាមវត្តអារាមនានាប្រកាសសេចក្តីកាន់ព្រះមរណទុក្ខ តាំងព្រះឆាយាល័ក្ខណ៍ និងធ្វើបុណ្យ សូត្រធម៌

www.elibraryofcambodia.org

ឧទ្ទិសព្រះរាជកុសលថ្វាយព្រះវិញ្ញាណក្ខន្ធជាហូរហែ។ មុខក្រសួង មន្ទីរ ស្ថាប័នរាជការ ក្រុមហ៊ុន ឯកជន និងផ្ទះសម្បែង ដាក់តាំងព្រះឆាយាល័ក្ខណ៍ ហើយហូតទង់ជាតិទៅត្រឹមស្មើរពាក់កណ្ដាលដង។

ព្រះបរមសពតម្កល់ក្នុងព្រះទីនាំងមហាមន្ទីរនៅផ្នែកខាងក្រោយនៃព្រះទីនាំងទេវាវិនិច្ឆ័យក្នុងព្រះបរមរាជវាំង ធ្វើបុណ្យរៀងរាល់ថ្ងៃរយៈពេល៣ខែ។ រៀងរាល់ថ្ងៃមានថ្នាក់ដឹកនាំនិងសមាជិកព្រឹទ្ធសភា, រដ្ឋសភា, រាជរដ្ឋាភិបាល, តុលាការ, មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ អញ្ជើញចូលថ្វាយបង្គំព្រះបរមសព។ រាជទូត, អគ្គទូត, ប្រតិភូមកពីប្រទេសនានា, ថ្នាក់ដឹកនាំស្ថាប័នអន្តរជាតិ, អង្គការផ្សេងៗជាដើមក៏អញ្ជើញចូលគោរពព្រះបរមសពជាហូរហែឥតដាច់។ ក្នុងឱកាសធ្វើកិច្ចប្រជុំថ្នាក់កំពូលអាស៊ាននិងប្រទេសដៃគូជាច្រើនទៀត នៅរាជធានីភ្នំពេញពីពាក់កណ្ដាលខែវិច្ឆិកា ឆ្នាំ២០១២ទៅ មានថ្នាក់ដឹកនាំកំពូលៗជាច្រើននោះ យាងនិងអញ្ជើញចូលថ្វាយបង្គំព្រះបរមសពដោយឡែកៗពីគ្នារៀងរាល់ថ្ងៃ។ បន្ទាប់ទៅមានគណៈអភិបាលខេត្ត ក្រុងនានា អភិបាលស្រុក មេឃុំ ប្រជារាស្ត្រទូទៅ និងព្រះសង្ឃជាដើម តែងនិមន្តនិងអញ្ជើញជាក្រុមរៀងៗខ្លួន ចូលថ្វាយបង្គំព្រះបរមសពតាមម៉ោងពេលកំណត់គ្មានលស់មួយថ្ងៃសោះឡើយ។ រាល់ពេលរាល់វេលាដែលប្រតិភូគ្រប់បែបយ៉ាងនិងនាម៉ឺនសព្វមុខមន្ត្រី ព្រមទាំងប្រជាពលរដ្ឋទាំងពួងចូលថ្វាយបង្គំព្រះបរមសពតែងតែមានវត្តមានព្រះករុណាជាអម្ចាស់ និងព្រះមាតា ឬក៏ព្រះអង្គម្ចាស់ ព្រះរាជវង្សានុវង្សយាងចាំទទួល តាមឋានៈបុណ្យយសគ្រប់ពេលទាំងអស់។

នៅខាងក្រៅព្រះបរមរាជវាំងខាងមុខប្រាសាទច័ន្ទឆាយាឯណោះវិញ មានប្រជាពលរដ្ឋសព្វបែបយ៉ាង អញ្ជើញមកពីគ្រប់ទិសទីក្នុងព្រះរាជាណាចក្រកម្ពុជាច្រើនឡើងៗរៀងរាល់ថ្ងៃ ពេលព្រឹក ពេលថ្ងៃ ល្ងាច និងយប់ មកអុជធូប អុជទៀន

www.elibraryofcambodia.org

ថ្វាយផ្កាឈូក សូត្រធម៌ សមាធិ ធ្វើបុណ្យ ធ្វើកុសលគ្រប់បែបយ៉ាងដោយទឹកចិត្តជ្រះថ្លា ស្មោះស និងក្តីរំជួលចិត្តរៀងៗខ្លួន ឧទ្ទិសព្រះរាជកុសលថ្វាយព្រះវិញ្ញាណក្ខ័ន្ធព្រះមហាវីរក្សត្រជាទីសក្ការៈ និងជាទីស្រឡាញ់ដ៏ជ្រាលជ្រៅក្នុងដួងចិត្តរបស់ខ្លួន (រូបលេខ១៧៧_១៧៨)។ មានមនុស្សម្នាជាច្រើន ទាំងប្រជារាស្ត្រសាមញ្ញ ទាំងសិស្ស



រូបលេខ១៧៧៖ ប្រជារាស្ត្រមកអុជធូប អុជទៀន ថ្វាយផ្កា អង្គុយសូត្រធម៌ រៀងរាល់ថ្ងៃ នៅមុខព្រះបរមរាជវាំង។



រូបលេខ១៧៨៖ ផ្កាឈូកដែលប្រជាពលរដ្ឋយកមកថ្វាយនៅមុខព្រះឆាយាល័ក្ខណ៍ព្រះមហាវីរក្សត្រ រៀងរាល់ថ្ងៃ នៅប្រាសាទច័ន្ទឆាយានៃព្រះបរមរាជវាំង។

និស្សិតជាដើមកោរសក់កាន់ទុក្ខនៅចំពោះមុខព្រះឆាយាល័ក្ខណ៍ព្រះមហាវីរក្សត្រ ដែលគេតម្កល់នៅលើប្រាសាទច័ន្ទឆាយានៃព្រះបរមរាជវាំង (រូបលេខ១៧៩) និងអ្នកខ្លះទៀតកោរសក់ ហើយអញ្ជើញមកថ្វាយគ្រឿងសក្ការបូជាចំពោះព្រះអង្គក៏មាន។ រយៈពេល៣ខែ មានមនុស្សច្រើនកុះករទៅមកឥតដាច់នៅខាងមុខព្រះបរមរាជវាំង ដើម្បីបានធ្វើកិច្ចគោរពព្រះវិញ្ញាណក្ខ័ន្ធព្រះអង្គ។



រូបលេខ១៧៩៖ សិស្ស និស្សិត ប្រជារាស្ត្រសាមញ្ញទូទៅខ្លះមកកោរសក់នៅមុខព្រះឆាយាល័ក្ខណ៍ កាន់ទុក្ខព្រះមហាវីរក្សត្រ។

www.elibraryofcambodia.org

នៅល្ងាចថ្ងៃសៅរ៍ ៥កើត ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០១២ មានព្រះសង្ឃប្រហែល៦០០០អង្គ និងប្រជាពលរដ្ឋរាប់ម៉ឺននាក់ និមន្តនិងអញ្ជើញមកជួបជុំនៅទីលានមុខព្រះបរមរាជវាំងខាងមុខប្រាសាទច័ន្ទឆាយា (រូបលេខ១៨០_១៨៣) ដើម្បីធ្វើកិច្ចសូត្រធម៌ បង្សុកូល ធ្វើសមាធិ ឧទ្ទិសព្រះរាជកុសលថ្វាយព្រះវិញ្ញាណក្ខ័ន្ធ។



រូបលេខ១៨០៖ ព្រះសង្ឃប្រហែល៦០០០អង្គ និងប្រជាពលរដ្ឋរាប់ម៉ឺននាក់ និមន្តនិងអញ្ជើញមកជួបជុំសូត្រធម៌ ថ្វាយព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខ័ន្ធ នៅមុខព្រះបរមរាជវាំង។



រូបលេខ១៨១៖ ព្រះសង្ឃតាំងសមាធិថ្វាយព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខ័ន្ធ មុខព្រះបរមរាជវាំង នៅល្ងាចថ្ងៃសៅរ៍ ៥កើត ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ (២០.១០.១២)។



រូបលេខ១៨២៖ ប្រជាពលរដ្ឋតាំងសមាធិថ្វាយព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខ័ន្ធព្រះមហាវីរក្សត្រ នៅមុខព្រះបរមរាជវាំង។



រូបលេខ១៨៣៖ ទាំងព្រះសង្ឃ ទាំងប្រជាពលរដ្ឋតាំងសមាធិនៅទីលានមុខព្រះបរមរាជវាំង ដើម្បីថ្វាយព្រះរាជកុសល។

www.elibraryofcambodia.org

នៅល្ងាចថ្ងៃអង្គារ ៨កើត ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ មានព្រះសង្ឃប្រហែលមួយម៉ឺនអង្គ និងប្រជាពលរដ្ឋរាប់ម៉ឺននាក់ និមន្តនិងអញ្ជើញមកជួបជុំនៅទីលានមុខព្រះបរមរាជវាំងខាងមុខប្រាសាទច័ន្ទឆាយា (រូបលេខ១៨៤) ដើម្បីធ្វើកិច្ចសូត្រធម៌បង្សុកូល ធ្វើសមាធិ ឧទ្ទិសព្រះរាជកុសលថ្វាយព្រះវិញ្ញាណក្ខ័ន្ធជាបន្តទៀត។



រូបលេខ១៨៤៖ ព្រះសង្ឃប្រហែលមួយម៉ឺនអង្គ និងប្រជាពលរដ្ឋរាប់ម៉ឺននាក់ និមន្តនិងអញ្ជើញមកជួបជុំសូត្រធម៌ ធ្វើសមាធិនៅទីលានមុខព្រះបរមរាជវាំង នៅល្ងាចថ្ងៃអង្គារ ៨កើត ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២។

រៀងរាល់ថ្ងៃ រាល់រាត្រីក្នុងរយៈពេល៣ខែកន្លះនេះ មានព្រះសង្ឃគ្រប់ឋានានុក្រមយ៉ាង និមន្តមកពីវត្តអារាមនានាធ្វើបុណ្យកុសល មានរាប់បាត្រ ប្រគេនចង្ហាន់និងទេយ្យទានផ្សេងៗ សូត្រធម៌សត្តប្បករណ៍ បង្សុកូល ពេលព្រឹក ហើយសូត្រព្រះអភិធម្មជាធម៌បទនៅរាល់រាត្រីដើម្បីថ្វាយព្រះរាជកុសលពុំដែលខានមួយពេលណាឡើយ។ រៀងរាល់ថ្ងៃមានធ្វើកិច្ចថ្វាយក្រយាព្រះស្ងោយ ហើយលាន់ឮសម្លេងស្ត្រី

www.elibraryofcambodia.org

យាំយាម និងភ្លេងក្លងជ្នះវង់រងៀមគួរស្រងេះស្រងោច ស្រណោះអាឡោះអាល័យក្រៃលែង។ នៅរៀងរាល់ថ្ងៃសីល ព្រះករុណាជាអម្ចាស់ និងព្រះមាតា ព្រមទាំងព្រះញាតិវង្ស អមដង្ហែដោយក្រុមអ្នករាំងផង តែងស្ដេចយាងចូលធ្វើកិច្ចពិធីផ្សេងៗថ្វាយព្រះបរមសពដោយផ្ទាល់ព្រះអង្គ ហើយមានក្រុមព្រាហ្មណ៍បារគូ៧រូបផ្លុំស័ង្ខថ្វាយព្រះពរជ័យទាំងពេលស្ដេចយាងដល់ ទាំងពេលស្ដេចយាងចាកព្រះទីនាំងមហាមន្ទីរ។

នៅថ្ងៃពុធ ១៥កើត ពេញបូណ៌មី ខែកត្ដិក ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា គ.ស.២០១២ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ រួមទាំងព្រះញាតិវង្ស ព្រមដោយសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី និងលោកជំទាវ ដែលមានសម្ដេចព្រះសង្ឃរាជទាំងពីរអង្គ និងរាជាគណៈសង្ឃតាមឋានានុក្រមសរុប៩០អង្គជាព្រះអធិបតីផង ប្រារព្ធព្រះរាជពិធីថ្វាយព្រះបច្ឆាមរណនាមព្រះបរមសពព្រះមហាវីរក្សត្រថា "ព្រះបរមរតនកោដ្ឋ" ដែលសូត្រព្រះរាជក្រឹត្យដោយសម្ដេចចៅហ្វាវាំងវរវៀងជ័យអធិបតីស្រីឧត្ដម គង់ សំអុល ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង។ បន្តបន្ទាប់មក មានកិច្ចពិធីធ្វើបុណ្យ ធ្វើកុសលដោយព្រះមហាក្សត្រ និងថ្នាក់ដឹកនាំធំៗរបស់ប្រទេសជាតិជាហូរហែឥតដាច់ឡើយ។

នៅឯទីវាលព្រះមេរុ ខាងជើង (ស្ថិតក្នុងផ្នែកក្បៀសាន) នៃព្រះបរមរាជវាំងនោះវិញ គេរៀបចំសាងព្រះមេរុដើម្បីត្រៀមធ្វើព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើងព្រះបរមសព។ នៅថ្ងៃព្រហស្បតិ៍ ២រោច ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា គ.ស.២០១២ មានធ្វើប្រុងពលី (សែនក្រុងពាលី) ដើម្បីផ្ដើមសាងព្រះមេរុ (រូបលេខ១៨៥-១៨៧)។ បន្ទាប់មកគេចាប់សាងព្រះមេរុតាមលំដាប់លំដោយ មានតួព្រះមេរុនៅកណ្ដាល ដែលប្រើគ្រឿងគ្រោងអំពីដែក(រូបលេខ១៨៨-

www.elibraryofcambodia.org



រូបលេខ១៨៥៖ ពិធីប្រុងពលី ឬសែនក្រុងពាលី សុំសាងព្រះមេរុនៅទីវាលព្រះមេរុខាងជើងព្រះរាជវាំង និងខាងមុខសារមន្ទីរជាតិ នៅថ្ងៃព្រហស្បតិ៍ ២រោច ខែអស្សុជ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា គ.ស.២០១២។



រូបលេខ១៨៦៖ គ្រឿងរណ្តាប់សម្រាប់សែនក្រុងពាលី សុំសាងព្រះមេរុនៅទីវាលព្រះមេរុ ខាងជើងព្រះបរមរាជវាំង (រូបថត៖ ជា សុជាតិ)។



រូបលេខ១៨៧៖ សម្តេចចៅហ្វាវាំងវរវៀងជ័យអធិបតីស្រីវង្គ្សារ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អញ្ជើញជាអធិបតីក្នុងពិធីសែនក្រុងពាលីសុំសាងព្រះមេរុ នៅទីវាលព្រះមេរុ (រូបថត៖ ជា សុជាតិ)។

www.elibraryofcambodia.org

១៨៩) ហើយនៅពេលសាងរួចរាល់ តួព្រះមេរុនេះមានក្បូរក្បាច់ល្អពិចិត្រណាស់ មានកម្ពស់ពីដីទៅកំពូលឆ័ត្រ៣រួត សរុប៤៦ម៉ែត្រ (រូបលេខ១៩០)។ មានក្បាច់រចនា ផ្កាហ្វា, ផង់ក្ដារ, នាគសន្ទឹក, នាគបែង, កញ្ចាំង, បាំងខ្វែង, អែវ៉ា ទេពនទយ (រូបលេខ១៩១_១៩២)។



រូបលេខ១៨៨៖ ចាក់បេតុងធ្វើជាគ្រឹះព្រះមេរុ។



រូបលេខ១៨៩៖ គ្រោងតួព្រះមេរុសាងអំពីដែក។



រូបលេខ១៩០៖ តួព្រះមេរុសាងរួចរាល់។

www.elibraryofcambodia.org



រូបលេខ១៩១៖ ក្បាលសសរ, ផ្តែរ, អែវ៉ាំនៃតួព្រះមេរុ សុទ្ធសឹងលម្អដោយក្បាច់រចនាពិចិត្រ។



រូបលេខ១៩២៖ អែវ៉ាំមាន រូបជាកិន្នរ លម្អលើក្បាល សសរ ទ្រដំបូលតួព្រះមេរុ។

នៅតាមកែងតួព្រះមេរុទាំង៤ទិសមានដងទង់ក្រពើខ្ពស់ទៅលើ មានរូបហង្សនិងឆត្ររួតជាដើម។ មានថែវព័ទ្ធជុំវិញ ដោយទុកច្រកចូលតាមទិសធំៗទាំង៤ (រូបលេខ១៩៣)។ នៅអែមពីមុខតួព្រះមេរុ មានព្រះពន្លាពីរសម្រាប់ព្រះមហាក្សត្រ និងព្រះញាតិវង្ស ព្រមទាំងថ្នាក់ដឹកនាំធំៗ រួមទាំងព្រះរាជាគណៈសង្ឃទាំងពីរគណៈ ក៏ដូចជារាជទូត អគ្គទូតនានាដែរ (រូបលេខ១៩៤_១៩៥) ឯនៅផ្នែកខាងលិចមានរោងភ្លេងពីរ (រូបលេខ១៩៦)។



រូបលេខ១៩៣៖ តួព្រះមេរុ និងថែវព័ទ្ធជុំវិញ គេដាក់ភ្លើងអគ្គិសនីលម្អនៅពេលយប់។



រូបលេខ១៩៤៖ ព្រះពន្លាពីរនៅអែមផ្លូវចូល ផ្នែកខាងកើតនៃតួព្រះមេរុ មើលពីទិសខាងជើង។

www.elibraryofcambodia.org



រូបលេខ១៩៥៖ ព្រះពន្លាខាងជើង។



រូបលេខ១៩៦៖ ផ្នែកខាងលិចនៃតួព្រះមេរុមានរោងភ្លេងពីរ មើលពីទិសខាងជើង។

នៅទិសខាងកើតមានខ្លោងទ្វារធំ ដែលយកគំរូតាមខ្លោងទ្វារជ័យនៃព្រះបរមរាជវាំង។ នៅពេលយប់មានដាក់ភ្លើងលម្អភ្លឺព្រោងព្រាយពេញព្រះមេរុ ធ្វើឱ្យមើលទៅឃើញរុងរឿងពេកកន្លង មានមនុស្សម្នាទៅមកគយគន់ព្រះមេរុដោយក្ដីស្ញប់ស្ញែង បុណ្យយសព្រះមហាវីរក្សត្រខ្លាំងណាស់។ ព្រះពន្លាខាងត្បូងមានកៅអីចំនួន៣១៨, ព្រះពន្លាខាងជើងមានកៅអីចំនួន៥៥៣ រីឯថែវព័ទ្ធជុំវិញតួព្រះមេរុទាំង៤ល្វែង មាន កៅអីចំនួន៣៩៨៤ ដូច្នេះសរុបកៅអីជាផ្លូវការក្នុងទីព្រះមេរុទាំងមូលមានចំនួនជិត៥០០០។

នៅល្ងាចថ្ងៃសៅរ៍ ១៥កើត ពេញបូណ៌មី ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៣ មានព្រះសង្ឃ២ម៉ឺនអង្គ និងប្រជាពលរដ្ឋប្រហែល១ម៉ឺននាក់ និមន្តនិងអញ្ជើញមកជួបជុំនៅមុខព្រះបរមរាជវាំង ខាងមុខប្រាសាទច័ន្ទឆាយា ហើយព្រះករុណាជាអម្ចាស់ និងព្រះមាតា ព្រមទាំងព្រះញាតិវង្សយាងចេញមក អមដង្ហែដោយនាម៉ឺនមន្ត្រីអ្នករាំងផង ដើម្បីធ្វើកិច្ចសូត្រធម៌ ធ្វើសមាធិឧទ្ទិសព្រះរាជកុសលថ្វាយព្រះវិញ្ញាណក្ខ័ន្ធ (រូបលេខ១៩៧_១៩៨) ដែលនៅតែ៥ថ្ងៃទៀតប៉ុណ្ណោះ ដល់ថ្ងៃហែព្រះបរមសពចាកព្រះបរមរាជវាំងទៅតម្កល់នៅព្រះមេរុ។

www.elibraryofcambodia.org



រូបលេខ១៩៧៖ ព្រះសង្ឃ២ម៉ឺនអង្គ និងប្រជាពលរដ្ឋប្រហែល១ម៉ឺននាក់ និមន្តនិងអញ្ជើញមកជួបជុំនៅមុខព្រះបរមរាជវាំង។



រូបលេខ១៩៨៖ ព្រះសង្ឃទាំងចាស់ទាំងក្មេងតាំងសមាធិថ្វាយព្រះរាជកុសល។

នៅថ្ងៃអាទិត្យ ១រោច ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦ ត្រូវនឹងថ្ងៃទី២៧ ខែមករា គ.ស.២០១៣ វេលាម៉ោង១២ថ្ងៃត្រង់ ព្រះជយាធិបតី កង់ កេន ជាមេក្រុមបារគូ ដឹកនាំធ្វើកិច្ចបួងសួងសុំព្រះភ្លើង។ គេរៀបគ្រឿងពលីការបូជាថ្វាយទេពទាំងពួង ហើយយកកែវពង្រីកមកតម្កល់លើពានបញ្ចាំងព្រះសូរ្យសែង រួចសូត្រសូមឱ្យព្រះតេជះព្រះអគ្និ (ព្រះអគ្គី) ចេះឡើង (រូបលេខ១៩៩_២០០) ទើបយកទៀនអុជចម្លង "ព្រះភ្លើង" ឬហៅថា "ភ្លើងកៃលាស" គឺព្រះភ្លើងបានមកពីស្ថានកៃលាសនោះដាក់ក្នុងលំផូងកែវ (រូបលេខ២០១_២០២) ហែយកទៅរក្សាទុកក្នុងហោព្រះវ័ន។



រូបលេខ១៩៩៖ ក្រុមបារគូធ្វើពិធីបួងសួងសុំព្រះភ្លើងពីសូរ្យសែងព្រះអាទិត្យ (រូបថត៖ ទទក)។



រូបលេខ២០០៖ ដាក់កែវបញ្ចាំងព្រះសូរ្យសែងឱ្យចេះឡើងជាព្រះភ្លើង (រូបថត៖ ទទក)។

www.elibraryofcambodia.org



រូបលេខ២០១៖ ព្រះភ្លើងឆេះឡើងក្នុងពាន ដែលដាក់កែវបញ្ចាំងព្រះសូរ្យសែង (រូបថត៖ ទទក)។



រូបលេខ២០២៖ ព្រះជយាធិបតី ជាមេក្រុមបារគូ ចម្លងព្រះភ្លើងដាក់ក្នុងលំផ្លង់កែវយកទៅរក្សាទុក (រូបថត៖ ទទក)។

លុះដល់វេលាព្រឹកព្រលឹមថ្ងៃសុក្រ ៦រោច ខែបុស្ស ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី១ ខែកុម្ភៈ គ.ស.២០១៣ ធ្វើកិច្ចរំកិលព្រះបរមសពព្រះបរមរតនកោដ្ឋចាកព្រះមហាមន្ទីរមកតម្កល់មុខព្រះមហាស្វេតច្ឆ័ត្រ រួចយាងនិងនិមន្តព្រះរាជាគណសង្ឃចូលថ្វាយព្រះសត្តប្បករណ៍។ បន្ទាប់មកក៏ចាប់ផ្ដើមពិធីរំកិល និងដង្ហែព្រះបរមសពចុះចាកព្រះទីនាំងទេវាវិនិច្ឆ័យ (រូបលេខ២០៣) ដោយមានក្រុមបារគូថ្វាយស័ង្ខ៣បទលាន់ឮខ្ទរខ្ទារឡើង។ គ្រានេះមានព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងព្រះមហាក្សត្រីជាព្រះមាតាយាងជាព្រះអធិបតី ព្រមដោយព្រះរាជវង្សានុវង្ស និងប្រមុខរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា នាម៉ឺនសព្វមុខមន្ត្រីអមដង្ហែផង។ លុះយាងព្រះបរមសពមកតម្កល់លើព្រះរាជរថហើយ (រូបលេខ២០៤) មានក្រុមទាហាន១៨រូបឈរជាពីរជួរ (ម្ខាងៗ៩រូប) កាន់ពួរទាញរំកិលព្រះរាជរថទៅមុខចេញពីព្រះបរមរាជវាំងតាមខ្លោងទ្វារជ័យ (រូបលេខ២០៥) ដោយមានសម្ដេចព្រះសង្ឃរាជទាំងពីគណៈយាងនាំពីមុខ ហើយមានសម្ដេចក្រុមព្រះនរោត្តម រណឫទ្ធិ ជាអ្នកទូលស្បូវភ្លាំង (បច្ចុប្បន្នគេឲ្យកាន់សំពត់ទូ ឬហៅថាផាយោង ជាជំនួសវិញ) ឯសម្ដេចព្រះវៀម នរោត្តម បុប្ផាទេវី និងសម្ដេចព្រះរាជកន្និដ្ឋា នរោត្តម អរុណរស្មី

www.elibraryofcambodia.org



*រូបលេខ២០៣៖ រំកិលព្រះបរមសព ចុះចាកព្រះទីនាំងទេវាវិនិច្ឆ័យ។*



*រូបលេខ២០៤៖ តម្កល់ព្រះបរមសពលើព្រះរាជរថទៅ មុខព្រះទីនាំងទេវាវិនិច្ឆ័យ ដើម្បីរៀបក្បួនហែរចេញ។*

ជាអ្នកប្រាយលាជ យាងនាំមុខព្រះទីនាំង។ នៅលើព្រះទីនាំងតម្កល់ព្រះមញ្ជូសា មាន សម្តេចព្រះមហេស្សរា នរោត្តម ចក្រពង្ស និងបារគូមួយរូបឈរអមខាងស្តាំ ហើយ សម្តេចព្រះបរមរាមា នរោត្តម យុវនាថ និងបារគូមួយរូបឈរអមខាងឆ្វេង។ ព្រះ មហាក្សត្រនិងព្រះមហាក្សត្រីជាព្រះមាតា, សម្តេចអគ្គមហាធម្មពោធិសាល ជា ប្រធានព្រឹទ្ធសភា, សម្តេចអគ្គមហាពញាចក្រី ជាប្រធានរដ្ឋសភា, សម្តេចអគ្គមហា សេនាបតីតេជោ ជានាយករដ្ឋមន្ត្រី, សម្តេចចៅហ្វាវាំងវរវៀងជ័យអធិបតីស្រីង្គារ, ព្រះញាតិវង្ស ព្រមទាំងនាម៉ឺនធំៗ ហែតាមពីក្រោយព្រះទីនាំង រហូតដល់វិថីព្រះ ស៊ីសុវត្ថិក្បែរព្រះអង្គដងកើ *(រូបលេខ២០៦_២០៧)*។

លុះរំកិលផ្ទេរព្រះមញ្ជូសាពីព្រះរាជរថឡើងទៅតម្កល់លើព្រះរាជរថ បុស្បក *(រូបទាគរាជ៣៦)* រួចរាល់ហើយ *(រូបលេខ២០៨_២០៩)* ទើបព្រះករុណាជា អម្ចាស់ជីវិតលើត្បូង និងព្រះមហាក្សត្រីជាព្រះមាតា ស្តេចសូមយាងព្រះបរមសព

www.elibraryofcambodia.org



រូបលេខ២០៥៖ ក្រុមទាហាន១៨រូប (ម្ខាងៗ៩រូប) ទាញព្រួររំកិលព្រះរាជរថតម្កល់ព្រះបរមសពយាង ចេញពីព្រះបរមរាជវាំងតាមខ្លោងទ្វារជ័យ។



រូបលេខ២០៦៖ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ជាអ្នកទូលស្បៃភ្ជាប់ ហើយសម្តេចព្រះរៀម នរោត្តម បុប្ផាទេវី និងសម្តេចព្រះរាជកន្និដ្ឋា នរោត្តម អរុណរស្មី ជាអ្នកព្រាយលាជ យាងនាំមុខព្រះបរមសព។



រូបលេខ២០៧៖ សម្តេចព្រះមហេស្សរា នរោត្តម ចក្រពង្ស និងសម្តេចព្រះបរមរាមា នរោត្តម យុវនាថ ព្រមទាំងព្រាហ្មណ៍បារគូ ឈរអមព្រះមញ្ជូសា។



រូបលេខ២០៨៖ រំកិលព្រះរាជរថតម្កល់ព្រះបរមសព ទៅទន្ទឹមនឹងព្រះរាជរថបុស្បក។

រូបលេខ២០៩៖ រំកិលព្រះមញ្ជូសា នៃព្រះបរមសពឡើងទៅតម្កល់ លើព្រះរាជរថបុស្បក។



www.elibraryofcambodia.org

ហែទៅកាន់ព្រះមេរុ។ គ្រានោះ ក្រុមព្រាហ្មណ៍បារគូបន្ទឹស័ង្ខ៣បទ ក្បួនដង្ហែក៏ផ្ដើមរំកិលសន្សឹមៗទៅមុខ រីឯស្គរធំ គងធំ ភ្លេងតូរ្យតន្ត្រីនានាប្រគំលាន់ឮគគ្រឹកគគ្រេងក្នុងក្បួនហែនោះ។ ក្បួនហែទាំងមូលចែកចេញជា១១សង្កាត់ធំៗ មានទាំងក្រុមអ្នកកាន់ទង់ជាតិធំ ទង់សាសនា ទង់ព្រះមហាក្សត្រ ស្គរជ័យ គងជ័យ បន្តហូរហែមកក្រុមកងទ័ពជើងគោក ជើងទឹក និងជើងអាកាស ព្រមទាំងកងយោធា នគរបាលសព្វបែបយ៉ាង។ មានទាំងក្រុមភ្លេងត្រៃទ័ព ភ្លេងក្រុមកាយឫទ្ធិ ក្រុមមន្ត្រីរាជការ ក្រុមចៅហ្វាយខេត្ត ក្រុមជាតិពន្ធនានាដែលជាពលរដ្ឋនគរខ្មែរ ដូចជាជនជាតិដើមនៅតំបន់ឦសានមានព្នង គ្រឹង ទំពួនជាដើម និងតំណាងជាតិសាសន៍ផ្សេងៗមានក្រុមចាម្ប, ក្រុមចិន, ក្រុមវៀតណាម។ល។ ហើយបន្តបន្ទាប់មកទៀតមានផែនមន្ត្រីរាជការ, ក្រុមអ្នកបួសមុខភ្លើង៩០រូប (ក្នុងនោះមានព្រះញាតិវង្ស២០អង្គ)។ តាមលំដាប់មកទៀតមានរថតែងគ្រឿងផ្សេងៗច្រើនបែប តម្កល់ព្រះចាយាលក្ខណ៍, តម្កល់ព្រះពុទ្ធរូប (ព្រះពុទ្ធ), តម្កល់ព្រះត្រៃបិដក (ព្រះធម៌), តម្កល់ត្រៃ (ព្រះសង្ឃ), តម្កល់គ្រឿងសម្រាប់រាជ្យ (មកុដរាជ្យ, ព្រះខ័នរាជ្យ, សុពណ៌បាទ...), រាជរថព្រះសង្ឃអភិធម្ម, រាជរថអ្នកប្រាយលាជ, រាជរថអ្នកទូលស្បូវភ្លាំង, ព្រះរាជរថបុស្បុក, រាជរថតម្កល់ខ្លឹមច័ន្ទន៍។ល។ ដូចឃើញគេរៀបត្រៀមទុកតាំងពីល្ងាចមុនមួយថ្ងៃ (រូបលេខ២១០)។



រូបលេខ២១០៖ ព្រះរាជរថផ្សេងៗ ត្រៀមតាមលំដាប់ទុកហែព្រះបរមសពទៅកាន់ទីព្រះមេរុ។

www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ ហៃ គឹមសៀន
ខែ វិច្ឆិកា ឆ្នាំ២០១៦
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្មៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org